ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ការគ្រប់គ្រងធនធានមនុស្ស
# ក្នុងរដ្ឋបាលសាធារណៈ

**បណ្ឌិត ស៊ិន សុឃន** អនុរដ្ឋលេខាធិការ
ក្រសួងមុខងារសាធារណៈ( ទទួលបន្ទុក បច្ចេកទេស រដ្ឋបាលនិងការទូត )
សាស្ត្រាចារ្យសាលាភូមិន្ទរដ្ឋបាល និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ខែមីនា ឆ្នាំ២០២៥

# លក្ខណៈទូទៅ នៃមុខងារសាធារណៈ

- ✓ សញ្ញាណទូទៅនៃមុខងារសាធារណៈ Notion of Civil Service
- ✓ និយមន័យ"មុខងារសាធារណៈ" Definition " Civil Service"
- មុខងារសាធារណៈ (Civil Service) ៖ ជាសារព័ន (សំណុំ)មន្ត្រីរាជការក្របខណ្ឌរដ្ឋទាំងថ្នាក់កណ្តាល ទាំងថ្នាក់ដែនដីដែលស្ថិតនៅក្រោមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លក្ខន្តិកៈដោយឡែក និងលិខិតបទដ្ឋានដទៃទៀត ចាប់តាំងពីថ្ងៃចូលបម្រើការងាររដ្ឋរហូតដល់ថ្ងៃចូលនិវត្តន៍។ ក្នុងរយៈពេលបំពេញការងាររបស់ខ្លួន មន្ត្រីរាជការមានសិទ្ធិទទួលបៀវត្ស ។

- **សមាសភាគមុខងារសាធារណៈ** Civil Service Components

✓ **និយមន័យទី១ ៖** មន្ត្រីរាជការ (Civil Servant) គឺជាបុគ្គលដែលតែងតាំងនៅក្នុងមុខតំណែងអចិន្ត្រៃយ៍ និងតាំងស៊ប់ក្នុងមុខតំណែងក្នុងឋានន្តរស័ក្តិ តាមឋានានុក្រម។

✓ **និយមន័យទី២ ៖** មន្ត្រីរាជការសំដៅលើបុគ្គលដែលតែងតាំងក្នុងការងារអចិន្ត្រៃយ៍ និងត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌនៃឋានានុក្រមរដ្ឋបាលរបស់រដ្ឋឬគ្រឹះស្ថានសាធារណៈ។

✓ **និយមន័យទី៣៖** មន្ត្រីរាជការ គឺជាអ្នកដែលបានជ្រើសរើសដោយប្រឡងប្រជែងឱ្យចូលក្នុងក្របខ័ណ្ឌបង្កើតឡើងដោយព្រះរាជក្រឹត្យបានចូលបម្រើការងារនៅក្នុងក្រសួង/ស្ថាប័នណាមួយ និងបានទទួលប្រាក់សោធននិវត្តន៍។

○ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា Cambodian Civil Servants

○ ភាពខុសគ្នារវាងមន្ត្រីរាជការស៊ីវិលនិងមន្ត្រីនយោបាយ The Differences between Civil Servant and Politician.

# លក្ខណៈពិសេសនៃមុខងារសាធារណៈ

មុខងារសាធារណៈមានលក្ខណៈពិសេស ៣ យ៉ាង

- បេសកកម្មរបស់មុខងារសាធារណៈ
- មធ្យោបាយរបស់មុខងារសាធារណៈ
- ប្រសិទ្ធភាពនៃសកម្មភាពរបស់មុខងារសាធារណៈ។

# គោលការណ៍មុខងារសាធារណៈ

គោលការណ៍មុខងារសាធារណៈមាន ៣ យ៉ាង គឺ ៖

- បំរើផលប្រយោជន៍សាធារណៈ
- គោរពគោលការណ៍ស្តីពី ឋានានុក្រម
- ការពារផលប្រយោជន៍របស់មន្ត្រីរាជការ។

# ប្រព័ន្ធមុខងារសាធារណៈ

## Civil Service Systems

❖ **ប្រព័ន្ធនិយោជន៍ឬប្រព័ន្ធបើកចំហ** (Employment System or Open System)

- ប្រព័ន្ធមុខងារសាធារណៈ "បើកចំហ" មានលក្ខណៈដូចគ្នានិងមុខងារឯកជនដែរ ប្រព័ន្ធនេះពឹងផ្អែកទៅលើមុខនាទី (Position based system)។
  - ✓ ប្រជាពលរដ្ឋអាចចូលធ្វើការទាំងការងាររដ្ឋ និង ការងារឯកជន ។
  - ✓ ការកំណត់ប្រាក់បៀវត្សទៅតាមតំលៃទីផ្សារការងារ និងតាមកិច្ចសន្យា ដែលជាទូទៅមានរយៈពេលខ្លី។
  - ✓ ប្រព័ន្ធនេះត្រូវបានគេអនុវត្តនៅក្នុងប្រទេសមួយចំនួនដូចជាសហរដ្ឋអាមេរិក ប្រទេស ស្វីស ប្រទេសកាណាដា« (លើកលែងរដ្ឋ Quebec) ប្រទេសម៉ិចសិក និងបណ្តាប្រទេសសង្គមនិយមមួយចំនួន។

- **ប្រព័ន្ធវិជ្ជាជីវៈក្របខ័ណ្ឌ ឬ ប្រព័ន្ធអាជីព ឬ ប្រព័ន្ធបិទ**

  ( Professional System or Close System )

- ជាគោលការណ៍ ប្រព័ន្ធនេះធ្វើការជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបំរើការងារនៅក្នុងមុខងារសាធារណៈ តាមការប្រលងប្រជែងចូលទៅក្នុងក្របខ័ណ្ឌមួយដែលគ្រប់គ្រងដោយរដ្ឋ ហើយការជ្រើសរើសនោះត្រូវកំណត់ តាមសេចក្ដីត្រូវការរបស់ក្រសួងស្ថាប័ន ដែលកំណត់នៅក្នុងផែនការរដ្ឋ។

- **ប្រព័ន្ធចំរុះ៖** ក្នុងការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្ន បណ្តាប្រទេសមួយចំនួនបានប្រកាន់យកប្រព័ន្ធចំរុះ គឺអនុវត្តន៍ប្រព័ន្ធទាំងពីរលើប្រភេទផ្សេងៗនៃមន្ត្រីរាជការរបស់គេដូចជាករណីប្រទេសអាឡឺម៉ង់ជាដើម ។

- **ប្រព័ន្ធមុខងារសាធារណៈនៅប្រទេសកម្ពុជា៖** ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារ (អាជីព និងនិយោជន៍)

# ប្រវត្តិនៃមុខងារសាធារណៈកម្ពុជា

## History of Cambodian Civil Service

- ប្រវត្តិនៃការគ្រប់គ្រងមុខងារសាធារណៈកម្ពុជាតាមសម័យកាលនីមួយៗមានដូចខាងក្រោម ៖

- មុខងារសាធារណៈ មុនសម័យបារាំងដាក់អាណានិគម
- មុខងារសាធារណៈ សម័យសង្គមរាស្ត្រនិយម
- មុខងារសាធារណៈ សម័យសាធារណរដ្ឋខ្មែរ
- មុខងារសាធារណៈ សម័យកម្ពុជាប្រជាធិបតេយ្យ
- មុខងារសាធារណៈ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា-រដ្ឋកម្ពុជា
- មុខងារសាធារណៈ សម័យព្រះរាជាណាចក្រកម្ពុជាទី២

# ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

Administrative Situation Change of Civil Servants Management

## ❑ ការរៀបចំការប្រឡងប្រជែងជ្រើសរើស Recruitment in Civil Service

- លក្ខខណ្ឌនៃការជ្រើសរើសត្រូវបានកំណត់ក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលរួមមាន សញ្ជាតិ អាយុ កំរិតសញ្ញាបត្រ ជំនាញឯកទេស ភាពជាពលរដ្ឋ កាយសម្បទាគ្រប់គ្រាន់ ហើយនៅប្រទេសខ្លះមានលក្ខខណ្ឌបំពេញបន្ថែមដូចជាការបំពេញកាតព្វកិច្ចយោធា។
- បេក្ខជនទាំងពីរភេទមានសិទ្ធិដូចគ្នាក្នុងការចូលរួមប្រលងប្រជែង តាមលក្ខខណ្ឌជ្រើសរើសដែលមានចែងក្នុងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ ការជ្រើសរើសអោយ ចូលបម្រើការងារក្នុងមុខងារសាធារណៈ គឺតាមគោលការណ៍ប្រលងប្រជែង និង តាមលក្ខខណ្ឌពិសេសដែលកំណត់ដោយរាជរដ្ឋាភិបាល។

# លក្ខខ័ណ្ឌនៃការជ្រើសរើស
## Condition for Recruitment

**ក-សញ្ជាតិខ្មែរ** (Khmer Nationality)

- ✓ មានភាពស្មោះត្រង់ គិតគូរដល់ផលប្រយោជន៍សាធារណៈឬ ប្រយោជន៍ជាតិ
- ✓ សញ្ជាតិខ្មែរពីកំណើត ឬសញ្ជាតូបនីយកម្ម

## ខ- អាយុ Age

✓ ល័ក្ខខ័ណ្ឌកំណត់ផ្នែកវេជ្ជសាស្ត្រ : កាយសម្បទា + សមត្ថភាពខាងបញ្ញាស្មារតី

+ លទ្ធភាពទទួលខុសត្រូវពីអំពើរបស់ខ្លួន

- ✓ ៣៥ ឆ្នាំ ថ្នាក់បរិញ្ញាបត្រ
- ✓ ៤០ ឆ្នាំ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
- ✓ មិនគិតលក្ខខណ្ឌអាយុ ថ្នាក់បណ្ឌិត

✓ អញ្ញត្រកម្ម: ➧វរជនពិសេស( តម្រូវការជាអាទិភាព + ផលប្រយោជន៍ជាតិ)

➧ សំរេចដោយរាជរដ្ឋាភិបាល (មាត្រា ៦១ , ៦២ CS)

# តួនាទីរបស់ក្រសួង ស្ថាប័នសាមី និងក្រសួងមុខងារសាធារណៈ

១.ក្រ.ម.សផ្ញើលិខិតទៅ
គ្រប់ក្រសួង-ស្ថាប័នដើម្បី
រៀបចំផែនការឆ្នាំបន្ទាប់

២.ក្រសួង-ស្ថាប័នបញ្ជូន
ចំនួនផែនការមក ក្រ.ម.ស

៣.ក្រ.ម.សរៀបចំប្រជុំ
ជាមួយក្រសួងស្ថាប័ន
នីមួយៗ

៤.ប្រជុំអន្តរៈក្រសួងដើម្បី
សម្រេចផែនការក្របខ័ណ្ឌ

៥.ក្រ.ម.ស រៀបចំគម្រោង
ផែនការក្របខ័ណ្ឌសរុប

៦.ប្រមុខងរាជរដ្ឋាភិបាល
សម្រេចផែនការក្របខ័ណ្ឌ

៧.ក្រ.ម.ស ចេញលិខិត
បែងចែកផែនការក្របខ័ណ្ឌ
ទៅគ្រប់ក្រសួង-ស្ថាប័ន

៨.ក្រសួងមុខងារសាធារណៈ
រៀបចំបង្កើតគណៈកម្មការ និងអនុ
គណៈកម្មការប្រឡងអន្តរក្រសួង
ដែលពាក់ព័ន្ធ

# និយាមនីតិវិធីប្រតិបត្តិ

## សម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល

និយាមនីតិវិធីប្រតិបត្តិនេះ គឺជាឧបករណ៍គតិយុត្តមូលដ្ឋានសម្រាប់អនុវត្តក្នុងការរៀបចំការប្រឡងប្រជែងជ្រើសរើសបានមន្ត្រីរាជការស៊ីវិល ដែលមានចំណេះដឹងជំនាញ និងសមត្ថភាពពិតប្រាកដ ស្របតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គឺ "**ជាប់ដោយមោទនភាព ធ្លាក់ដោយអស់ចិត្ត**"។

- . **គោលការណ៍ទូទៅ**

ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ត្រូវអនុវត្តផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- គោលការណ៍គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព
- សេចក្តីត្រូវការពិតប្រាកដនៃការងាររបស់អង្គភាពនៃក្រសួង ស្ថាប័ន
- មុខតំណែង និងគុណវុឌ្ឍិជាក់លាក់នៃមុខតំណែង
- ការពិពណ៌នាច្បាស់លាស់អំពីមុខតំណែង
- ចំនួនជាក់លាក់នៃមុខតំណែងនីមួយៗដែលត្រូវជ្រើសរើស

- អង្គភាពបំពេញការងារជាក់លាក់
- ទីតាំងភូមិសាស្ត្រដែលបេក្ខជនត្រូវទៅបំពេញការងារ
- ឥណទានថវិកាដែលបានអនុម័តក្នុងច្បាប់ថវិកាប្រចាំឆ្នាំ

ការផ្តល់អាទិភាពដល់បេក្ខជនមានលក្ខណៈសម្បត្តិសមស្រប ដែលមានពិការភាព ជាស្ត្រី អ្នករស់នៅតំបន់ដាច់ស្រយាល ជនជាតិដើមភាគតិច និងមន្ត្រីជាប់កិច្ចសន្យាដែលបម្រើការងារក្នុងរដ្ឋបាលសាធារណៈ។

## វិធានការគន្លឹះចំនួន៣ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ រួមមាន៖

1. **ការដាក់ចេញឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រី** ចូលរួមប្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាព
2. **ការពង្រឹងសមត្ថភាពនិងសមិទ្ធកម្មស្ថាប័ន** ដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
3. **ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម** ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។

# ការងារអាទិភាពមួយចំនួនរបស់ក្រសួងមុខងារសាធារណៈ ក៏ដូចជា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចតទៅ៖

- ដឹកនាំ គ្រប់គ្រង និង អភិវឌ្ឍវិស័យមុខងារសាធារណៈត្រូវខិតខំអនុវត្តតួនាទី មុខងារ និង ភារកិច្ចរបស់ខ្លួនឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ ដោយគោរពយ៉ាង ខ្ជាប់ខ្ជួននូវ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និង គោលការណ៍របស់រាជរដ្ឋាភិបាល។
- ត្រូវបន្តអនុវត្តការងារប្រឡងជ្រើសរើសមន្ត្រីផ្អែកលើ គោលការណ៍អនុញ្ញាតរបស់រាជរដ្ឋាភិបាល ដោយអនុលោមតាមនិយាមនីតិវិធី ប្រតិបត្តិស្តីពីការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិល និងធានាដល់បេក្ខជន "ជាប់ដោយមោទនៈ ធ្លាក់ដោយអស់ចិត្ត" ព្រមទាំងបន្តជំរុញការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការជ្រើសរើស និងគ្រប់គ្រងមន្ត្រីបច្ចេកទេស/ជំនាញ ផ្អែកលើកិច្ចព្រមព្រៀងការងារឱ្យឆ្លើយតបនឹងគោលការណ៍ "ការបំពេញឱ្យត្រូវ ថែរក្សាឱ្យនៅ" និង "ប្រសិទ្ធភាពនៃការអនុវត្តការងារ" ។

- ត្រូវបន្តសហការក្នុងការ ជំរុញដំណើរការនៃការពិនិត្យឡើងវិញនៃការវិភាគមុខងារ និង រចនាសម្ព័ន្ធក្រសួង ស្ថាប័ន ដោយផ្តោតលើមុខងារ, រចនាសម្ព័ន្ធ, សេវា, អភិក្រមការងារ, ធនធាន មនុស្ស និង ថវិកាឱ្យសម្រេចបាននូវលទ្ធផលកែលម្អជាក់ស្តែងជាបណ្តើរៗ ក្នុង ការលើកកម្ពស់ប្រសិទ្ធភាព និង គុណភាពការងារដោយគោរពយ៉ាងម៉ឺងម៉ាត់នូវអភិ ក្រម "រៀបចំផ្ទះឱ្យរៀបរយ" និង "ពង្រឹងជាជាងពង្រីក"។
- ត្រូវបន្តជំរុញការរៀបចំ និងការដាក់ឱ្យអនុវត្តប្រព័ន្ធ លើកទឹកចិត្តគាំទ្រសមិទ្ធកម្មរដ្ឋបាល សាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងសមិទ្ធផលការងារនៅតាមក្រសួងស្ថាប័ន។
- គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូថ្នាក់ជាតិ ត្រូវបន្តគាំទ្រ និងជំរុញ ចលនាប្រឡងប្រណាំងអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យ អប់រំ និងវិស័យសុខាភិ បាល ព្រមទាំងផ្សព្វផ្សាយនូវឧត្តមានុវត្តន៍ និងនវានុវត្តន៍ នៃការដឹកនាំ និងគ្រប់គ្រងអង្គ ភាពឱ្យកាន់តែទូលំទូលាយ ដើម្បីរួមចំណែក ក្នុងការលើកកម្ពស់ប្រសិទ្ធភាព និង គុណ ភាពនៃដំណើរការរបស់អង្គភាព។

- ត្រូវដឹកនាំ និងសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ដើម្បីអនុវត្តយុទ្ធនាការបច្ចុប្បន្នភាពរចនាសម្ព័ន្ធជាក់ស្ដែងរបស់ ក្រសួងស្ថាប័ន និងការជំរឿនមន្ត្រីជាក់ស្ដែងនៅតាមរចនាសម្ព័ន្ធក្រសួងស្ថាប័ន ដើម្បីកំណត់ឱ្យបានជាក់លាក់នូវព័ត៌មាន និង ទិន្នន័យគ្រប់ជ្រុងជ្រោយនិងប្រកប ដោយគុណភាព ដើម្បីគាំទ្រ ដល់ការអនុវត្តវិធានការកែលម្អក្រសួងស្ថាប័ន ការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស និងហិរញ្ញវត្ថុ និង ការបំពេញមុខងារកាន់តែ មានប្រសិទ្ធភាពខ្ពស់។
- ត្រូវដឹកនាំសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និង កីឡា ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តយុទ្ធនាការ បច្ចុប្បន្នភាពគ្រឹះស្ថានអប់រំសាធារណៈនៅមូលដ្ឋាន រួមមាន វិទ្យាល័យ អនុវិទ្យាល័យ សាលាបឋមសិក្សា និងមត្តេយ្យសិក្សា និងការជំរឿនមន្ត្រី ជាក់ស្ដែងនៅតាមគ្រឹះស្ថានទាំងនេះ ដើម្បីកំណត់ឱ្យបានជាក់លាក់នូវព័តមាន និង ទិន្នន័យគ្រប់ជ្រុងជ្រោយ និងប្រកបដោយគុណភាព ដើម្បីគាំទ្រដល់ការអនុវត្តវិធានការកែលម្អស្ថាប័ន ការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស និងថវិកា និង ការផ្ដល់សេវាអប់រំមូលដ្ឋានកាន់តែមានប្រសិទ្ធភាព។

- ត្រូវដឹកនាំ និងសម្របសម្រួលជាមួយក្រសួងសុខាភិបាល ក្រសួងស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីអនុវត្តយុទ្ធនាការបច្ចុប្បន្ន ភាពអង្គភាពសុខាភិបាលនៅមូលដ្ឋាន រួមមាន មន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំ សកម្មភាពបង្គ្រប់កម្រិត ១, កម្រិត ២, កម្រិត ៣, មណ្ឌលសុខភាព និង ការជំរឿន មន្ត្រីជាក់ស្តែងនៅតាមអង្គភាពទាំងនេះ ដើម្បីកំណត់ឱ្យបាននូវព័តមាន និងទិន្នន័យ គ្រប់ជ្រុងជ្រោយ និង ប្រកបដោយគុណភាព ។
- ត្រូវបន្តផ្តល់ការគាំទ្រ ដឹកនាំសម្របសម្រួល និង ជំរុញការអភិវឌ្ឍធនធានមនុស្ស ក្នុងរដ្ឋបាលសាធារណៈ, ជាពិសេស ការពង្រឹង សមត្ថភាពដឹកនាំ និងគ្រប់គ្រងអង្គភាពសាធារណៈនៅតាមក្រសួងស្ថាប័ន និង ថ្នាក់ក្រោមជាតិ ឱ្យឆ្លើយតបនឹងតម្រូវការនៃការងារជាក់ស្តែង និងទស្សនវិស័យ នៃការកែទម្រង់រដ្ឋបាលសារធារណៈរបស់រាជរដ្ឋាភិបាល ។
- ក្នុងនាមជាស្ថាប័នទទួលបន្ទុកលើការងារកែទម្រង់ រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល ត្រូវបន្តពង្រឹងកិច្ចសហការឱ្យកាន់តែជិតស្និទ្ធ ផ្តល់ការគាំទ្រ និង សម្របសម្រួលឱ្យកាន់តែប្រសើរ ជាមួយគ្រប់ការដ្ឋានកែទម្រង់ របស់រាជរដ្ឋាភិបាល ដើម្បីធានានូវសង្គតិភាព សុខដុមនីយកម្ម និង ប្រសិទ្ធភាពខ្ពស់ នៃការអនុវត្តគោលនយោបាយ និង ផែនការយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល។

# គោលការណ៍នៃការជ្រើសរើស

- ការកំណត់តម្រូវការនៃការជ្រើសរើសមន្ត្រីរាជការស៊ីវិល
- លក្ខខណ្ឌសម្រាប់បេក្ខជនចូលរួមក្នុងការប្រឡងប្រជែង
- ប្រតិទិននៃការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល
- ការកំណត់វិញ្ញាសាសម្រាប់ការប្រឡងប្រជែង
- ការគ្រប់គ្រងដំណើរការប្រឡងប្រជែង
- ដំណើរការនៃការរៀបចំការប្រឡងប្រជែង
- បទប្បញ្ញត្តិនិងសេចក្តីណែនាំពាក់ព័ន្ធនឹងដំណើរការប្រឡងប្រជែង
- ការស្នើសុំពិនិត្យឯកសារ និង សន្លឹកកិច្ចការរបស់បេក្ខជន
- ការបណ្តុះបណ្តាល និងការរៀបចំកម្មសិក្សា

## ❑ របនាសម្ព័ន្ធនយោបាយ និង រដ្ឋបាល

**ថ្នាក់ជាតិ**

- គណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ
- អគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន/គ្រឹះស្ថានសាធារណៈរដ្ឋបាល
- នាយកដ្ឋាន
- ការិយាល័យ

# ថ្នាក់ក្រោមជាតិ

- រដ្ឋបាលរាជធានី ខេត្តៈ (ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨)
  - ក្រុមប្រឹក្សា
  - គណៈអភិបាល និង អង្គភាពរដ្ឋបាល
  - មន្ទីរ
  - ការិយាល័យ
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
  - ក្រុមប្រឹក្សា
  - គណៈអភិបាល និងអង្គភាពរដ្ឋបាល
  - ការិយាល័យ
- ឃុំ សង្កាត់ (ផ្អែកលើកម្មវិធីកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ រចនាសម្ព័ន្ធស្ថាប័ន មានការប្រែប្រួលពីឆ្នាំ ២០០២ តាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ ២០០១ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០១)
  - ក្រុមប្រឹក្សា
  - មេឃុំ ចៅសង្កាត់
  - ស្មៀនឃុំ សង្កាត់

# ប្រភេទនៃលិខិតរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្ត

| (១)លិខិតរដ្ឋបាល | (២)លិខិតបទដ្ឋានគតិយុត្ត |
| --- | --- |
| - លិខិតស្នើ<br>- លិខិតឆ្លើយតប<br>- សេចក្តីជូនដំណឹង<br>- លិខិតអញ្ជើញ<br>- លិខិតបង្គាប់ការ<br>- លិខិតបញ្ជាបេសកកម្ម<br>- លិខិតចុះទិដ្ឋាការធ្វើដំណើរ<br>- លិខិតផ្ទេរសិទ្ធិ<br>- លិខិតប្រគល់សិទ្ធិចុះហត្ថលេខា<br>- ដីកាអម ឬដីកាបញ្ជូន<br>- លិខិតសុំច្បាប់និងអនុញ្ញាតច្បាប់<br>- កំណត់បង្ហាញរឿង<br>- របាយការណ៍<br>- កំណត់ហេតុ<br>- លិខិតបញ្ជាក់ | - រដ្ឋធម្មនុញ្ញ<br>- ច្បាប់ធម្មនុញ្ញ<br>- ក្រម<br>- ច្បាប់<br>- ព្រះរាជក្រឹត្យ<br>- អនុក្រឹត្យ<br>- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល<br>- សារាចររបស់រាជរដ្ឋាភិបាល<br>- សារាចរណែនាំរបស់រាជរដ្ឋាភិបាល<br>- បទបញ្ជារបស់រាជរដ្ឋាភិបាល<br>- ប្រកាស<br>- ប្រកាសអន្តរក្រសួង<br>- សេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន<br>- សារាចររបស់ក្រសួង ស្ថាប័ន<br>- សារាចរអន្តរក្រសួង<br>- សេចក្តីណែនាំ<br>- ដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- សេចក្តីសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- សេចក្តីណែនាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

## ➢ រចនាសម្ព័ន្ធបៀវត្ស៖

- បៀវត្សមូលដ្ឋាន
- ប្រាក់បំណាច់មុខងារ
- ប្រាក់វិភាជគ្រួសារ៖ ប្រាក់ឧបត្ថម្ភប្រពន្ធ និង កូន
- ប្រាក់តំបន់ សម្រាប់តែវិស័យអប់រំ និង សុខាភិបាល
- ប្រាក់ឧបត្ថម្ភផ្អែកលើសមិទ្ធកម្មការងារ អនុវត្តសម្រាប់វិស័យដែលពាក់ព័ន្ធនឹងការប្រមូលចំណូល និង ការងារអាទិភាព

# ការតំឡើងតម្លៃសន្ទស្សន៍បៀវត្សមូលដ្ឋាន( គិតជាប្រាក់រៀល )



# ទិន្នន័យក្របខណ្ឌ និងឥណទានបៀវត្ស

ចំនួនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេស តាមភេទ និងប្រភេទក្របខណ្ឌ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២៥




| | សរុប | ក្របខណ្ឌក | ក្របខណ្ឌខ | ក្របខណ្ឌគ | ប្រភេទផ្សេងៗ |
|---|---|---|---|---|---|
| ថ្នាក់ជាតិ | 54,585 | 33,437 | 8,467 | 3,431 | 9,250 |
| ស្ត្រីថ្នាក់ជាតិ | 16,576 | 9,852 | 3,774 | 1,263 | 1,687 |
| សរុបថ្នាក់ក្រោមជាតិ | 177,449 | 38,969 | 66,408 | 71,981 | 31 |
| ស្ត្រីថ្នាក់ក្រោមជាតិ | 81,312 | 12,703 | 29,774 | 38,824 | 11 |

ថ្នាក់ជាតិ ស្ត្រីថ្នាក់ជាតិ សរុបថ្នាក់ក្រោមជាតិ ស្ត្រីថ្នាក់ក្រោមជាតិ

# សិទ្ធិពលរដ្ឋ សិទ្ធិខាងរដ្ឋប្បវេណី និង សិទ្ធិនយោបាយ

- ✓ មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣
- ✓ បាត់បង់សិទ្ធិណាមួយ → មិនអាចក្លាយជាមន្ត្រីរាជការបាន
- ✓ សិទ្ធិពលរដ្ឋ៖ សិទ្ធិរស់រានមានជីវិត + សេរីភាព + សន្តិសុខផ្ទាល់ខ្លួន
- ✓ សិទ្ធិរដ្ឋប្បវេណី៖ សិទ្ធិកម្មសិទ្ធិ + សិទ្ធិអាពាហ៍ពិពាហ៍ + កាតព្វកិច្ចកើតពីកិច្ចសន្យា
- ✓ សិទ្ធិនយោបាយ ៖ សិទ្ធិបោះឆ្នោត + ឈរឈ្មោះបោះឆ្នោត + សិទ្ធិបង្កើតសមាគម
- ✓ បាត់បង់សិទ្ធិទាំងនេះ ←ការផ្តន្ទាទោសជាប់ពន្ធនាគារ ➧ មិនអាចធ្វើជាមន្ត្រីរាជការ
- ✓ មូលហេតុ៖ រក្សានូវកិត្តិយសនៃអំណាចសាធារណៈ + ផលប្រយោជន៍ជាតិ

# មានសីលធម៌ល្អ និង ភាពសុច្ចរិត

- ✓ មាត្រា១១-៤+ មាត្រា១២-២ CS
- ✓ ភាពសុច្ចរិត : លិខិតបញ្ជាក់ពីឃុំសង្កាត់( មានភាពសុច្ចរិតស្អាតស្អំនិងមានសីលធម៌ល្អ)

  + លិខិតថ្កោលទោស ( មានសុពលភាពរយៈពេល០៣ខែ)
- ✓ គោលបំណង:
  - ➢ជៀសវាង ជ្រើសរើសមនុស្សមានប្រវត្តិរូបអាក្រក់មកគ្រប់គ្រង
  - ➢ កុំអោយអាប់អោនដល់កិត្យានុភាពរដ្ឋបាល

## កាយសម្បទាគ្រប់គ្រាន់

- ✓ ទទួលខុសត្រូវ ៖ តាមតួនាទី ឬតំណែងរបស់ខ្លួន ➧ លិខិតពីពេទ្យការងារ
- ✓ ពិការភាព ➧ បាត់បង់កាយសម្បទា ➧ ច្បាប់ហាមឃាត់ក្នុងការជ្រើសរើសចូលរាជការ
- ✓ ការអនុវត្តសព្វថ្ងៃ៖ គិតគូរដល់សិទ្ធិរបស់ជនពិការ ➧ រើសមន្ត្រីពិការចូលក្នុង ក្របខ័ណ្ឌរដ្ឋ (ធ្វើការងារអាចធ្វើបាន)

## ជនមានអាទិភាព

- ✓ ជនជាតិភាគតិច
- ✓ ជនរស់នៅតំបន់ដាច់ស្រយាល
- ✓ នារីភេទ

# ការរៀបចំដាក់ឱ្យទទួលការបណ្តុះបណ្តាលវគ្គតម្រង់ទិស និងកម្មសិក្សា

**កម្មសិក្សា** Probationary Period

- ប្រលងជាប់+ រៀនចប់សាលាភូមិន្ទរដ្ឋបាល ➧ទទួលប្រកាសពី ក្រ-ម-ស (ចូលធ្វើការ)

  ➧ ជាកម្មសិក្សាការី

- កម្មសិក្សាការី ➧ជាមន្ត្រីរាជការមិនពេញលេញ ➧ ស្ថិតក្នុងស្ថានភាពសាកល្បងការងារ
- ក្នុងរយៈពេលកម្មសិក្សា ៖
  - ឧស្សាហ៍ព្យាយាមធ្វើការ
  - គោរពវិន័យបានល្អ
  - គោរពពេលវេលាធ្វើការ
  - មានសេចក្តីថ្លៃថ្នូរ មានសីលធម៌ល្អ
  - បង្ហាញអោយឃើញថាខ្លួនមានសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់

## រយៈពេលធ្វើកម្មសិក្សា ៖

- ✓ ១២ខែៈ(គិតពីថ្ងៃចូលធ្វើការដំបូង)ៈសិស្សនិស្សិត + មន្ត្រីរាជការ( មិនទាន់តាំងស៊ប់)
- ✓ ៦ខែ ៖
  - ➢ មន្ត្រីរាជការពីមុនមិនស្ថិតនៅក្នុងក្របខ័ណ្ឌក្រោមបន្ទាប់ក្របខ័ណ្ឌដែលខ្លួនប្រលង
  - ➢ មន្ត្រីរាជការប្រលងចូលក្របខ័ណ្ឌមកពីក្រសួងស្ថាប័នផ្សេង ( ក្របខ័ណ្ឌក្រសួងអប់រំ )

## 0ខែ ( មិនចាំបាច់ធ្វើកម្មសិក្សា) ករណី ៖

- ➢ មន្ត្រីពីមុនស្ថិតក្នុងក្របខ័ណ្ឌក្រោមបន្ទាប់
- ➢ ប្រលងប្រជែងចូលក្របខ័ណ្ឌថ្មីនៅក្នុងក្រសួងតែមួយ (តាមលក្ខន្តិកៈដោយឡែកខ្លះ)

- ការធ្វើកម្មសិក្សាមិនអាចយកជាការបាន ➧ អវត្តមានសរុបលើសពី ៣០ថ្ងៃ ៖
  - ត្រូវធ្វើកម្មសិក្សាបន្តទៀតតាមការកំណត់របស់អង្គភាព
  - កម្មសិក្សាបន្តនៅតែពុំបានទទួលជោគជ័យត្រូវ៖

-លុបឈ្មោះ ➧ សិស្សនិស្សិត

-បញ្ជូលទៅក្របខ័ណ្ឌដើម ➧ មន្ត្រីរាជការក្របខ័ណ្ឌ

-ការសំរេច ➡ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស

# ការតាំងស៊ប់ក្នុងក្របខណ្ឌ

## Permanent Employment /Confirmation in a grade

លិខិតបទដ្ឋានឯកត្តជន សំរាប់ផ្តល់ឋានន្តរស័ក្តិមួយនៃក្របខ័ណ្ឌដល់កម្មសិក្សាការី និងផ្តល់ឧបនិស្ស័យដល់មន្ត្រីនោះសំរាប់បំពេញមុខតំណែងស្របទៅនឹងឋានន្តរស័ក្តិខ្លួន ព្រមទាំងផ្តល់ឋានៈអោយបានក្លាយទៅជាមន្ត្រីរាជការស៊ីវិលពេញសិទ្ធិ ឬមន្ត្រីក្របខ័ណ្ឌ។

ឥទ្ធិពលតាំងស៊ប់៖

- ផ្តល់ឋានន្តរស័ក្តិមួយនៃក្របខ័ណ្ឌដល់កម្មសិក្សាការី
- ផ្តល់ឧបនិស្ស័យសំរាប់បំពេញមុខតំណែងស្របទៅនឹងឋានន្តរស័ក្តិខ្លួន
- ក្លាយជាមន្ត្រីក្របខ័ណ្ឌ

កម្មសិក្សាជោគជ័យ ➧ តាំងស៊ប់

- ការតាំងស៊ប់ ← ប្រកាសក្រសួងស្ថាប័នសាមី + យោបល់ពីគណៈកម្មការតាំងស៊ប់
- សំរេចក្នុងរយៈពេល៣ខែយ៉ាងយូរបន្ទាប់ពីបញ្ចប់កម្មសិក្សា
- ជា ពេលចាប់ផ្តើមគិតអតីតភាពសំរាប់ការឡើងឋានន្តរស័ក្តិ ថ្នាក់
- ករណីមិនផ្តល់ការតាំងស៊ប់ :
  - ✓ គ្មានសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់/ធ្វើការខ្ជីខ្ជា/គ្មានកំលាំងពលំគ្រប់គ្រាន់
  - ✓ ល្មើសបទបញ្ញត្តិដាក់វិន័យនៃCS(មាត្រា៣៣+ មាត្រាបន្តបន្ទាប់) +

    បទល្មើសព្រហ្មទ័ណ្ឌ ➧ ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មន្ត្រីរាជការ

    ➧ អាចប្តឹងទៅតុលាការ
  - ✓ មិនគោរពវិន័យ + មិនមកធ្វើការទៀងទាត់+ អត់សីលធម៌

# តារាងសង្ខេបអំពីក្រុមប័ណ្ណនីមួយៗ

| ប្រភេទក្រុមប័ណ្ណ | កម្រិតឋានានុក្រមនៃមុខតំណែង | លក្ខខណ្ឌអប្បបរមានៃការបណ្តុះបណ្តាល |
|---|---|---|
| ក | អ្នកដឹកនាំ អធិការកិច្ច សិក្សា ផ្តល់យោបល់ ទទួលខុសត្រូវ | (មធ្យមសិក្សាទុតិយភូមិ+៤) |
| ខ | ជំនួយការដឹកនាំ | (មធ្យមសិក្សាទុតិយភូមិ+២) |
| គ | លេខាធិការ អ្នកប្រតិបត្តិមានជំនាញ | (មធ្យមសិក្សាទុតិយភូមិ) |

# លក្ខន្តិកៈដោយឡែក

ប្រភេទក្របខណ្ឌនីមួយៗ (ក ខ គ) នៃលក្ខន្តិកៈដោយឡែក សម្រាប់វិស័យទាំង៦ និងចែកជា១៧ ក្របខណ្ឌ

| ប្រភេទក្របខណ្ឌ | ឈ្មោះក្របខណ្ឌ | | | | | |
|---|---|---|---|---|---|---|
| | រដ្ឋបាលទូទៅ | មហាផ្ទៃ | ការទូត | អប់រំ | សុខាភិបាល | បច្ចេកទេស |
| ក | មន្ត្រីគ្រប់គ្រងរដ្ឋបាល | មន្ត្រីរដ្ឋបាលជាន់ខ្ពស់ | មន្ត្រីការទូតជាន់ខ្ពស់ | គ្រូបង្រៀនកម្រិតឧត្តម | មន្ត្រីសុខាភិបាលជាន់ខ្ពស់ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ |
| ខ | មន្ត្រីក្រមការ | មន្ត្រីក្រមការ | មន្ត្រីក្រមការការបរទេស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | មន្ត្រីសុខាភិបាលមធ្យម | មន្ត្រីបច្ចេកទេសមធ្យម |
| គ | លេខាធិការរដ្ឋបាល | លេខាធិការរដ្ឋបាល | | គ្រូបង្រៀនកម្រិតបឋម | មន្ត្រីសុខាភិបាលបឋម | មន្ត្រីបច្ចេកទេសបឋម |

- ការតែងតាំង ការប្រគល់ភារកិច្ច ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែង

## ➢ ការតែងតាំង ការប្រគល់ភារកិច្ច ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងដោយថ្នាក់ជាតិ៖

- **ព្រះរាជក្រឹត្យ៖** អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ សាកលវិទ្យាធិការ អភិបាលរាជធានី ខេត្ត ឬ មុខតំណែងប្រហាក់ប្រហែល
- **អនុក្រឹត្យ៖** អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ប្រធាននាយកដ្ឋាន អភិបាលរងរាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ ឬ មុខតំណែងប្រហាក់ប្រហែល និងប្រធានមន្ទីររាជធានី ខេត្ត
- **ប្រកាស៖** អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យថ្នាក់កណ្តាល នាយករដ្ឋបាល ឬ មុខតំណែងប្រហាក់ប្រហែល។

- ការតែងតាំង ការប្រគល់ភារកិច្ច ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងដោយថ្នាក់ក្រោមជាតិ៖

ដឹការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត៖ អនុប្រធានមន្ទីររាជធានី ខេត្ត ប្រធានការិយាល័យនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬ មុខតំណែងប្រហាក់ប្រហែល

# ការឡើងថ្នាក់ និងឋានន្តរស័ក្តិ Grade and Step Promotion

- ការដំឡើងថ្នាក់របស់មន្ត្រីរាជការត្រូវធ្វើតាមវេនជ្រើសរើសក៏បាន ឬតាមវេនអតីតភាពឬតាមវេនជ្រើសរើសផងនិងវេនអតីតភាពផងក៏បាន។ អតីតភាពការងារនៅក្នុងការដំឡើងថ្នាក់ គឺគិតពីថ្ងៃតាំងស៊ប់នៅក្នុងក្របខ័ណ្ឌ។
- មន្ត្រីរាជការ ដែលបានដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌ ដើម្បីទៅបំពេញមុខងារជាសមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិករដ្ឋាភិបាល

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ...ត្រូវដំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិរៀងរាល់ ២ឆ្នាំម្តង។

- មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ដោយទទួលបានសញ្ញាបត្រ ដែលកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌរបស់ខ្លួនបានដំឡើងមួយថ្នាក់ជាស្វ័យប្រវត្តិ។

- ចំពោះមន្ត្រីក្របខ័ណ្ឌបច្ចេកទេសជាន់ខ្ពស់ ដែលបានបណ្តុះបណ្តាលរយៈពេល១ ឆ្នាំ និងមានសញ្ញាបត្រ ការឡើងថ្នាក់ត្រូវធ្វើឡើងបានម្តង ១ថ្នាក់។

# ប្រភេទអង្គនៃមន្ត្រីរាជការស៊ីវិល

ចំពោះមន្ត្រីរាជការស៊ីវិលបច្ចុប្បន្ន អង្គដែលបានបង្កើតរួចមាន៦៖

- អង្គរដ្ឋបាលទូទៅ
- អង្គរដ្ឋបាលក្រសួងមហាផ្ទៃ
- អង្គសុខាភិបាល
- អង្គការងារទូត
- អង្គបច្ចេកទេស
- អង្គគ្រូបង្រៀន។

# អគ្គរដ្ឋបាលទូទៅ

ក. ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល (ក)

- ឋានន្តរស័ក្តិ ឧត្តមមន្ត្រី (ក១)
- ឋានន្តរស័ក្តិ វរមន្ត្រី (ក២)
- ឋានន្តរស័ក្តិ អនុមន្ត្រី (ក៣)

ខ.ក្របខ័ណ្ឌមន្ត្រីក្រមការ (ខ)

- ឋានន្តរស័ក្តិ នាយក្រមការ (ខ១)
- ឋានន្តរស័ក្តិ ក្រមការដើមខ្សែ (ខ២)
- ឋានន្តរស័ក្តិ ក្រមការ (ខ៣)

គ. ក្របខ័ណ្ឌលេខាធិការរដ្ឋបាល (គ)

- លេខាធិការរដ្ឋបាល (គ)

# អន្តរដ្ឋបាលក្រសួងមហាផ្ទៃ

ក. ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ (ក)

- ឋានន្តរស័ក្តិ ឧត្តមមន្ត្រី (ក១)
- ឋានន្តរស័ក្តិ វរមន្ត្រី (ក២)
- ឋានន្តរស័ក្តិ អនុមន្ត្រី (ក៣)

ខ. ក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ (ខ)

- ឋានន្តរស័ក្តិ នាយក្រមការ (ខ១)
- ឋានន្តរស័ក្តិ ក្រមការដើមខ្សែ (ខ២)
- ឋានន្តរស័ក្តិ ក្រមការ (ខ៣)

គ. ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក្រសួងមហាផ្ទៃ (គ)

- លេខាធិការរដ្ឋបាល (គ)។

# អគ្គសុខាភិបាល

ក.ក្របមន្ត្រីសុខាភិបាលជាន់ខ្ពស់ (ក)

- ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស (ក១)
- ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ (ក២)
- ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ (ក៣)

ខ. ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម (ខ)

- ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលមធ្យមដើមខ្សែពិសេស (ខ១)
- ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលមធ្យមដើមខ្សែ (ខ២)
- ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលមធ្យម (ខ៣)

គ. ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម (គ)

- មន្ត្រីសុខាភិបាលបឋម (គ)

# អគ្គការទូត

## ក. ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ (ក)

- ឋានន្តរស័ក្តិ ឧត្តមមន្ត្រីការបរទេស (ក១)
- ឋានន្តរស័ក្តិ វរមន្ត្រីការបរទេស (ក២)
- ឋានន្តរស័ក្តិ អនុមន្ត្រីការបរទេស (ក៣)

## ខ. ក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស (ខ)

- ឋានន្តរស័ក្តិ នាយក្រមការការបរទេស (ខ១)
- ឋានន្តរស័ក្តិ ក្រមការដើមខ្សែការបរទេស (ខ២)
- ឋានន្តរស័ក្តិ ក្រមការការបរទេស (ខ៣) ។

# អន្តរប្បញ្ញត្តិ

ក. ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ (ក)

- ឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស (ក១)
- ឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ (ក២)
- ឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ (ក៣)

ខ. ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម (ខ)

- ឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស (ខ១)
- ឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ (ខ២)
- ឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសមធ្យម (ខ៣)

គ. ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម (គ)

- មន្ត្រីបច្ចេកទេសបឋម (គ)។

# អន្តរគ្រូបង្រៀន

ក. ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម (ក)

- ឋានន្តរស័ក្តិ គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស (ក១)
- ឋានន្តរស័ក្តិ គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ (ក២)
- ឋានន្តរស័ក្តិ គ្រូបង្រៀនកម្រិតឧត្តម (ក៣)

ខ. ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន (ខ)

- ឋានន្តរស័ក្តិ គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស (ខ១)
- ឋានន្តរស័ក្តិ គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ (ខ២)
- ឋានន្តរស័ក្តិ គ្រូបង្រៀនកម្រិតមូលដ្ឋាន (ខ៣)

គ. ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម (គ)

- គ្រូបង្រៀនកម្រិតបឋម (គ)។

# ការរៀបចំក្របខណ្ឌមន្ត្រីរាជការស៊ីវិល

## Organizing Civil Servant Cardre

- ក្របខណ្ឌត្រូវបានកែសម្រួលពី ៤ ប្រភេទ មកជា ៣ ប្រភេទ ៖ ក ខ និង គ
- ក្របខណ្ឌត្រូវរៀបចំផ្អែកលើមុខតំណែង ឬមុខងារនៃអង្គនីមួយៗ

  - កម្រិតនៃការបណ្តុះបណ្តាល ឬគុណសម្បត្តិវិជ្ជាជីវៈ

  - ការរៀបចំក្របខណ្ឌជាកម្រិត ផ្សារភ្ជាប់ជាមួយ នឹងកម្រិតនៃសេចក្តីត្រូវការនៃការងារក្នុងមុខតំណែងឬមុខងារដែលមន្ត្រីរាជការត្រូវបំពេញ

# ការរៀបចំឋានន្តរស័ក្តិមន្ត្រីរាជការ

## Organizing Civil Servant Grade

- ឋានន្តរស័ក្តិ ជាលំដាប់ឋានានុក្រមមន្ត្រីរាជការក្នុងក្របខណ្ឌ កនិង ខ ៖
  - ឋានន្តរស័ក្តិ ១
  - ឋានន្តរស័ក្តិ ២
  - ឋានន្តរស័ក្តិ ៣
- ឋានន្តរស័ក្តិបញ្ជាក់ឧបនិស្ស័យក្នុងការបំពេញមុខតំណែងឬ មុខងារ
- ក្របខណ្ឌ គ មិនមានការបែងចែកជាកម្រិតឋានន្តរស័ក្តិនោះទេ។

# ការរៀបចំថ្នាក់មន្ត្រីរាជការ

## Organizing Civil Servant Step

➢ឋានន្តរស័ក្តិ ក្នុងក្របខ័ណ្ឌ ក និង ខ ត្រូវបែងចែកជា ថ្នាក់ ៖

- ឋានន្តរស័ក្តិ ១ មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិ ២ មាន ៤ ថ្នាក់
- ឋានន្តរស័ក្តិ ៣ មាន ៤ ថ្នាក់

ការរៀបចំថ្នាក់ក្នុងឋានន្តរស័ក្តិនេះ ត្រូវបានធ្វើឡើងឈរលើការគិតគូរ (១)ស្ថានភាពនៃរចនាសម្ព័ន្ធឋានន្តរស័ក្តិ និងថ្នាក់បច្ចុប្បន្ន និង (២) ការវិវត្តន៍នៃអាជីព និងឧបនិស្ស័យក្នុងការទទួលមុខតំណែងគ្រប់គ្រង

➢ ក្របខណ្ឌ គ មានបែងចែកជា ១០ ថ្នាក់។

# ការរៀបចំថ្នាក់មន្ត្រីរាជការ
# Organizing Civil Servant Step

ថ្នាក់នីមួយៗ មានសន្ទស្សន៍ កំណត់កម្រិតបៀវត្សន៍មូលដ្ឋានរបស់មន្ត្រីរាជការ

- ក្របខណ្ឌ ក សន្ទស្សន៍ចាប់ពី ៣៤៥ ដល់ ៥៥០ គម្លាត១.៦ដង
- ក្របខណ្ឌ ខ សន្ទស្សន៍ចាប់ពី ៣០០ ដល់ ៤៧០ គម្លាត១.៦ ដង
- ក្របខណ្ឌ គ សន្ទស្សន៍ចាប់ពី ២៦៥ ដល់ ៣៩០ គម្លាត១.៥ដង
- គម្លាតសន្ទស្សន៍ខ្ពស់បំផុត និងទាបបំផុតគឺ២ ដង
- ជាមធ្យម មន្ត្រីរាជការស៊ីវិលនឹងទទួលបានកំណើនសន្ទស្សន៍ចំនួន១២ សម្រាប់ក្របខណ្ឌ ខ និង គ និង ១៥ សម្រាប់ក្របខណ្ឌ ក ក្នុងពេលទទួលការដំឡើងថ្នាក់ ១ ថ្នាក់។

- ការគណនាចំនួនទឹកប្រាក់សម្រាប់បៀវត្សរ៍ មូលដ្ឋាន គឺយកតម្លៃឯកតានៃសន្ទស្សន៍គុណជាមួយនឹងចំនួនសន្ទស្សន៍។ ចំនួនសន្ទស្សន៍មានកំណត់ ក្នុងតារាងដែលប្រែប្រួលទៅតាមប្រភេទក្របខ័ណ្ឌឋានន្តរស័ក្តិនិងថ្នាក់របស់មន្ត្រីរាជការ។
- ឧទាហរណ៍ការគិតប្រាក់បៀវត្សមូលដ្ឋានសម្រាប់មន្ត្រី ដែលមានឋានន្តរស័ក្តិ អនុមន្ត្រីថ្នាក់ទី៤ មន្ត្រីនេះមានសន្ទស្សន៍ ៣៤៥ និងតម្លៃឯកតានៃសន្ទស្សន៍ ២៦៣០រៀល។ ដូច្នេះប្រាក់បៀវត្សមូលដ្ឋាន = ២៦៣០៛ x ៣៤៥ = ៩០៧ ៣៥០ រៀល
- ចំពោះមន្ត្រីរាជការគ្រប់រូបមានសិទ្ធិទទួលប្រាក់បៀវត្សមូលដ្ឋានតែក្នុងលក្ខខណ្ឌមួយចំនួន ដូចជាកំពុងបំពេញសកម្មភាពការងារ កំពុងផ្លាស់ប្តូរកន្លែងធ្វើការនៅក្នុងឬក្រៅប្រទេសកំពុងធ្វើដំណើរទៅកាន់មុខតំណែងឬកំពុងវិលត្រឡប់មកវិញ។

# តារាងកម្រិតសន្ទស្សន៍បៀវត្សថ្មីរបស់មន្ត្រីរាជការស៊ីវិល

## List of new Civil Servant Wage Scales

| ប្រភេទក្របខ័ណ្ឌ | ឋានន្តរស័ក្តិ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក<br>មន្ត្រីគ្រប់គ្រងរដ្ឋបាល | ៣ - អនុមន្ត្រី | | | | ២ - វរៈមន្ត្រី | | | | ១ - ឧត្តមមន្ត្រី | | | | | |
| | ថ្នាក់ | | | | ថ្នាក់ | | | | ថ្នាក់ | | | | | |
| | ៤ | ៣ | ២ | ១ | ៤ | ៣ | ២ | ១ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| | សន្ទស្សន៍បៀវត្ស | | | | សន្ទស្សន៍បៀវត្ស | | | | សន្ទស្សន៍បៀវត្ស | | | | | |
| | ៣៤៥ | ៣៥៤ | ៣៦៤ | ៣៧៩ | ៣៩៤ | ៤១០ | ៤២៦ | ៤៤៣ | ៤៦១ | ៤៧៩ | ៤៩៦ | ៥១៣ | ៥៣១ | ៥៥០ |

| ប្រភេទក្របខ័ណ្ឌ | ឋានន្តរស័ក្តិ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ខ<br>មន្ត្រីក្រមការ | ៣ - ក្រមការ | | | | ២ - ក្រមការដើមខ្សែ | | | | ១ - នាយក្រមការ | | | | | |
| | ថ្នាក់ | | | | ថ្នាក់ | | | | ថ្នាក់ | | | | | |
| | ៤ | ៣ | ២ | ១ | ៤ | ៣ | ២ | ១ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| | សន្ទស្សន៍បៀវត្ស | | | | សន្ទស្សន៍បៀវត្ស | | | | សន្ទស្សន៍បៀវត្ស | | | | | |
| | ៣០០ | ៣០៨ | ៣១៨ | ៣៣១ | ៣៤៤ | ៣៥៨ | ៣៦៩ | ៣៨០ | ៣៩៣ | ៤០៧ | ៤២១ | ៤៣៦ | ៤៥៣ | ៤៧០ |

| ប្រភេទក្របខ័ណ្ឌ | ឋានន្តរស័ក្តិ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| គ<br>លេខាធិការរដ្ឋបាល | ថ្នាក់ | | | | | | | | | |
| | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| | សន្ទស្សន៍បៀវត្ស | | | | | | | | | |
| | ២៦៥ | ២៧៤ | ២៨៤ | ២៩៥ | ៣០៧ | ៣២១ | ៣៣៥ | ៣៥២ | ៣៧០ | ៣៩០ |

# ការរៀបចំមុខតំណែងមន្ត្រីរាជការ

## Organizing Civil Servant Position

- មុខតំណែងត្រូវបានកំណត់សម្រាប់ប្រភេទការងារ ហើយដែលត្រូវផ្សារភ្ជាប់ជាមួយនឹង ៖

  -ឈ្មោះមុខតំណែង

  -ការរៀបចំអំពីការងារ អង្គភាពនិងទីកន្លែងបំពេញការងារ

  -គុណសម្បត្តិសម្រាប់មុខតំណែង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់

- ការកំណត់មុខតំណែងមានផលដោយផ្ទាល់លើ ៖

  -ការបង្កើនប្រសិទ្ធភាពចំណាយសម្រាប់បន្ទុកបុគ្គលិក

  -បង្កើតមូលដ្ឋានច្បាស់លាស់សម្រាប់ការវាយតម្លៃសមិទ្ធកម្ម

# ការរៀបចំមុខតំណែងមន្ត្រីរាជការ

## Organizing Civil Servant Position

- កំណត់បាននូវគម្លាតរវាងសមត្ថភាពជំនាញនិងសេចក្តីត្រូវការនៃការងារ ដែលអាចនឹងបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការកសាងសមត្ថភាព
- គាំទ្រដល់អភិក្រមនៃការជ្រើសរើសដោយត្រឹមត្រូវ និងមានប្រសិទ្ធភាព
- ជាមូលដ្ឋាននៃការកំណត់ប្រាក់កម្រៃសម្រាប់ប្រភេទការងារ
- ការកំណត់មុខតំណែងជាការងារស្មុគស្មាញ លំបាក ទាមទារពេលវេលា ប៉ុន្តែជាការងារដែលចាំបាច់ត្រូវសម្រេចឱ្យបាន។

# ✍ ភាពធំនៃរត់គេចពីការងារដោយបញ្ញត្តិ

✓ ក្នុងករណីដូចតទៅ :

➤ បោះបង់ការងារ ឬអវត្តមានដោយគ្មានច្បាប់អនុញ្ញាតរយៈពេល ១៥ ថ្ងៃជាប់គ្នា

( ប្រធានស្ថាប័នរំលឹកសាមីខ្លួនយ៉ាងហោចណាស់ 0២ ដង)

➤ ត្រូវបានតុលាការជំនុំជំរះៈមានទោសពីបទឧក្រិដ្ឋឬបទមជ្ឈិម + បានប្តឹងឧទ្ធរណ៍រហូតដល់ថ្ងៃមានសាលក្រមចុងក្រោយបង្អស់

➤ រយៈពេលៈ

-មិនលើសពី 0៣ ខែ ឡើយ

-ផុតរយៈពេល៣ខែ +មិនត្រឡប់ទៅបំពេញការងារវិញ ( ដាក់កំហិតអោយចូលធ្វើការតាមការកំណត់ពីរដង) ➧ ត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌ

## ✍ភាពទំនេរគ្មានបៀវត្សរ៍ដោយមានពាក្យសុំ

- ✓ ទូទៅៈ ➧ អនុញ្ញាត( លើកលែងមានការចាំបាច់របស់ក្រសួង-ស្ថាប័ន)
- ✓ រយៈពេលៈ ( ចែកជា២តាមមូលហេតុ) :
  - ➢ មិនតិចជាង ០៦ ខែ និងមិនលើសពី ២ ឆ្នាំ + អាចបន្តសារជាថ្មីតែរយៈពេលសរុបទាំងអស់មិនអោយហួសពី ០៤ ឆ្នាំ :

☝ **មូលហេតុ :**

- ទៅធ្វើការនៅក្នុងផ្នែកឯកជន ឬធ្វើការងារជាប្រយោជន៍សាធារណៈ

-ដើម្បីធ្វើការសិក្សានិងស្រាវជ្រាវនៅក្នុង ឬក្រៅប្រទេស + បំរើផលប្រយោជន៏ទូទៅ

-ផលប្រយោជន៏ផ្ទាល់ខ្លួន

- ០៣ ខែ និងមិនលើសពី ២ ឆ្នាំ + អាចបន្តជាថ្មីមិនហួសពី ០៤ ឆ្នាំ :

**មូលហេតុ :**

-ទៅថែទាំងសហព័ទ្ធ ឬកូនដែលមានជំងឺធ្ងន់

-ទៅរួមរស់ជាមួយសហព័ទ្ធជាមន្ត្រីរាជការក្នុងករណីសុំផ្លាស់មិនទាន់បាន

✍ លក្ខខណ្ឌនៃការចាប់ផ្តើមឈប់ និងការវិលចូលបំរើការងារវិញ :

- ✓ មានប្រសិទ្ធិភាពនៅថ្ងៃទី ០១ នៃខែបន្ទាប់មានការយល់ព្រមពីអាជ្ញាធរ
- ✓ ដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស២ខែមុនពេលផុតកំណត់
- ✓ មិនបានដាក់ពាក្យសុំបន្ត + មិនបានចូលបំរើការងារវិញក្រោយពេលផុតកំណត់
  - ➧ ចាត់ទុកថាបោះបង់ចោលការងារ + លុបឈ្មោះពីក្របខ័ណ្ឌចាប់ពីថ្ងៃនោះតទៅ
- ✓ ដាក់ពាក្យសុំចូលបំរើការងារមុនពេលកំណត់ ➧ បាន/រង់ចាំកន្លែងទំនេរ
- ✓ ចូលបំរើការងារវិញ ➧ ទទួលកន្លែងទំនេរ សមស្រប និងឋានន្តរស័ក្តិរបស់ខ្លួន
- ✓ សេចក្តីសំរេចចូលបំរើការងារឡើងវិញ ឬបញ្ឈប់ពីការងារ ➧ **ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស**

# ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើមឬស្ថិតនៅក្រៅតំណែង

## Placement on Dismemberment from his/her Cardre/Position

- លិខិតបទដ្ឋានឯកជនសម្រាប់ដាក់មន្ត្រីរាជការឱ្យនៅក្រៅក្របខ័ណ្ឌដើម ដោយផ្អាកទទួលបៀវត្សក្នុងក្របខណ្ឌនេះ ប៉ុន្តែទទួលបៀវត្សក្នុងក្របខណ្ឌថ្មីដែលសាមីខ្លួនទៅបម្រើការងារនិងបន្តសិទ្ធិតម្លើងថ្នាក់ឋានន្តរស័ក្តិ និងសិទ្ធិសម្រាប់ចូលនិវត្តន៍នៅក្នុងក្របខណ្ឌដើមរបស់ខ្លួន។

**ឥទ្ធិពល :**

- ✓ មន្ត្រីទៅធ្វើការកន្លែងផ្សេង
- ✓ ផ្អាកបៀវត្សក្នុងក្របខណ្ឌចាស់:
  - ➧ ទទួលបៀវត្សក្នុងក្របខ័ណ្ឌថ្មី
  - ➡ ឬ ផ្ទេរបៀវត្សចុងក្រោយ+ប្រាក់បំណាច់មុខងារតំណែងថ្មី (មានក្របខ័ណ្ឌ)

- ✓ រក្សាសិទ្ធិតម្លើងថ្នាក់ + ឋានន្តរស័ក្តិ + សិទ្ធិចូលនិវត្តន៍នៅក្នុងក្របខ័ណ្ឌដើម

ក្របខ័ណ្ឌថ្មី រឺ មុខតំណែងថ្មី ៖

- ✓ សមាជិករាជរដ្ឋាភិបាល +រដ្ឋលេខាធិការ + អនុរដ្ឋលេខាធិការ
- ✓ តំណាងរាស្ត្រ
- ✓ ទីប្រឹក្សាគ្រប់ឋានានុក្រម
- ✓ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រុង-ស្រុក-ខ័ណ្ឌ ខេត្ត- រាជធានី
- ✓ មន្ត្រីខុទ្ទកាល័យរបស់ប្រធានស្ថាប័ន
- ✓ មន្ត្រីរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ- ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រុង-ស្រុក-ខ័ណ្ឌ ខេត្ត-រាជធានី

## នីតិវិធីៈ

- ពេលចាប់ផ្តើមៈ
  - ទទួលបានការតែងតាំងតំណែងថ្មី រឺ ក្របខ័ណ្ឌថ្មី
  - ដាក់ពាក្យសុំតាមឋានានុក្រមទៅបំរើការងារនៅក្រៅក្របខ័ណ្ឌដើម
  - ចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី
- អត្ថប្រយោជន៏ ៈ
  - បៀវត្សៈ
    - ទទួលបៀវត្សក្នុងក្របខ័ណ្ឌថ្មី
    - រឺផ្ទេរបៀវត្សចុងក្រោយ+ប្រាក់បំណាច់មុខងារតំណែងថ្មី

- រក្សាសិទ្ធិដំឡើង ឋានន្តរស័ក្តិ ឬថ្នាក់
- សិទ្ធិទទួលសោធននិវត្តន៍សុំចូលនិវត្តន៍បើដល់អាយុ
- បើចូលនិវត្តន៍ + បន្តធ្វើការក្រៅក្របខ័ណ្ឌដើម ➡ ទទួលប្រាក់សោធននិវត្តន៍

  (បៀវត្សរកន្លែងថ្មី អនុក្រឹត្យលេខ៤១)

✓ ពេលបញ្ចប់ការងារ (ចប់អាណតិ ឬលាឈប់)

➤ ដាក់ពាកដាក់ពាក្យចូលធ្វើការក្នុងក្របខណ្ឌដើមវិញ

➤ ចូលបំរើការងារវិញដោយរក្សាឋានន្តរស័ក្តិ និងថ្នាក់ដែលក្រសួង-ស្ថាប័នដើម

បន្តរៀបជូន

# ១០ ការបញ្ចេញពីក្របខ័ណ្ឌ Removal from his/her Body

- គឺជាស្ថានភាពមួយដែលមន្ត្រីរាជការបញ្ចប់នូវអាជីពការងារជាអ្នករាជការរបស់ខ្លួន
- ផលប៉ះពល ➧ បញ្ចប់អាជីពជាមន្ត្រីអ្នករាជការ
- មូលហេតុ ០៦ យ៉ាងគឺ :
  - ✓ ការឈប់ពីការងារដោយស្ម័គ្រចិត្ត
  - ✓ ការចូលនិវត្តន៍ដោយការដល់អាយុ តាមការស្នើសុំ និងដោយបញ្ញត្តិ
  - ✓ ការបាត់បង់សម្បទាវិជ្ជាជីវៈ
  - ✓ ទទួលមរណៈភាព
  - ✓ ទទួលទណ្ឌកម្មវិន័យថ្នាក់ទី២
  - ✓ អវត្តមានក្រោយចប់ភាពទំនេរគ្មានបៀវត្ស

# ការផ្លាស់ប្តូរកន្លែងធ្វើការនិងការផ្ទេរក្របខណ្ឌ

## Change of Assignment and Cadre Transfer

- **ការផ្លាស់ប្តូរកន្លែងធ្វើការ** Change of Assignment

គឺជាការប្តូរកន្លែងធ្វើការពីអង្គភាពមួយទៅអង្គភាពមួយទៀតនៅក្នុងក្របខ័ណ្ឌក្រសួងតែមួយ ដូចជាការប្តូរពី ខេត្តមួយទៅខេត្តមួយ ការប្តូរមកធ្វើការនៅទីស្តីការក្រសួង ឬពីអង្គភាពមួយទៅអង្គភាពមួយនៅក្នុងក្រសួងតែមួយ ។

លក្ខខ័ណ្ឌ(ប្រែប្រួលតាមការកំណត់របស់ក្រសួង + ស្ថានភាពគ្រប់គ្រងធនធានមនុស្សរបស់ក្រសួងនីមួយៗ) មានដូចជា :

- ✓ អតីតភាពអប្បរមា ➧ តាមការកំណត់របស់ក្រសួងស្ថាប័ន + តាមទីកន្លែងធ្វើការ

- ផ្លាស់ប្ដូរកន្លែងធ្វើការក្នុងហេតុផលតាមសហព័ទ្ធ
- មានហេតុផលគ្រប់គ្រាន់អាចពិចារណាបាន
- ក្រសួងខ្លះមានបង្កើតជាគណៈកម្មការផ្លាស់ប្ដូរកន្លែងធ្វើការ + គណៈកម្មការតាមដានការងារសហព័ទ្ធ ➧ ការផ្លាស់ប្ដូរមានប្រសិទ្ធិភាព ( ក្រសួងអប់រំ)

## ❑ ការផ្ទេរក្របខណ្ឌ Cardre Transfer

- ការផ្ទេរក្របខ័ណ្ឌ និងកន្លែងធ្វើការរបស់មន្ត្រីរាជការពីក្រសួងស្ថាប័នមួយទៅក្រសួងស្ថាប័នមួយទៀត។
- ផលប៉ះពាល់: ✓ ប្តូរកន្លែងធ្វើការទៅក្រសួងផ្សេង
  ✓ ផ្ទេរក្របខណ្ឌទៅក្រសួងផ្សេង
  ✓ មិនអាចផ្ទេរតំណែង+ប្រាក់បំណាច់មុខងារទេ

- ការផ្ទេរមន្ត្រីរាជការ និងផ្លាស់ប្តូរកន្លែងធ្វើការ ៖មន្ត្រីរាជការក្របខ័ណ្ឌអាចផ្ទេរពីក្រសួងស្ថាប័នមួយទៅក្រសួងស្ថាប័នមួយទៀតតាមការស្នើសុំរបស់សាមីខ្លួន ឬតាមតម្រូវការការងារដោយទទួល ឯកភាពពីក្រសួងសាមីទាំង២ និងដោយមានការយល់ព្រមពីក្រសួងមុខងារសាធារណៈ។

- ការផ្ទេរមាន២ករណី :
  - ✓ តាមការស្នើសុំរបស់សាមីខ្លួន
  - ✓ តាមតំរូវការការងារដោយមានការឯកភាពរបស់ក្រសួងសាមីទាំង២
- គោលការណ៍:
  - ✓ អាស្រ័យលើតំណែងទំនេរក្នុងស្ថាប័នមួយទៀត /សំណូមពរការងារចាំបាច់
  - ✓ អតីតភាពអប្បរមាអាចផ្ទេបាន ( អប់រំ ៧ឆ្នាំ )
  - ✓ ឯកភាពពីថ្នាក់ដឹកនាំតាមឋានុក្រមរបស់ក្រសួងទាំងពីរ+ឯកភាពពីក្រ.ម.ស ( ប្រធានមន្ទីរ → មានយោបល់ឯកភាពពីអាជ្ញាធរដែនដីចាំបាច់ )
  - ✓ មិនមែនមន្ត្រីរាជការស៊ីវិល + កំពុងបំរើការងារក្នុងរដ្ឋបាលស៊ីវិល ➧ អាចផ្ទេរមករដ្ឋបាលស៊ីវិលបាន → បណ្តុះបណ្តាលវគ្គវិក្រឹត្យការនៅសាលាភូមិន្ទរដ្ឋបាលជាមុន

- ការផ្ទេរពីរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយផ្សេងទៀត
- ការផ្ទេររវាងរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ផ្អាកការផ្ទេរចេញពីរចនាសម្ព័ន្ធរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ទៅមន្ទីរ អង្គភាពរបស់ក្រសួង
- ផ្អាកការផ្ទេរមន្ត្រីរាជការដែលកំពុងបំពេញការងារនៅតាមមណ្ឌលសុខភាព។
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរក្សាប្រក្រតីភាព និងនិរន្តរភាពការងារនៅតាមសាលាមត្តេយ្យសិក្សា សាលា បឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ និងអង្គភាពនីមួយៗ ដោយមិនត្រូវធ្វើការផ្លាស់ប្តូរ ឬការផ្ទេរមន្ត្រីនៅតាមសាលា មជ្ឈមណ្ឌល និងអង្គភាពទាំងនោះឡើយ។

# គុណសម្បត្តិ នៃឥរិយាបថរបស់មន្ត្រីរាជការ

## ( Value of Civil Servant )

- ក្នុងគោលបំណងបម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើង ដើម្បីសុខុមាលភាព របស់ប្រជាពលរដ្ឋ និងវិបុលភាពរបស់ប្រទេសជាតិយើងត្រូវប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជា «**អ្នកផ្តល់សេវាដ៏មានប្រសិទ្ធិភាពជូនប្រជាពលរដ្ឋ**» និងផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតពីភាពជា «**អ្នកត្រួតត្រា និងអ្នកត្រូវគេត្រួតត្រា**» ឱ្យទៅជា«**អ្នកផ្តល់សេវា និងអ្នក ប្រើប្រាស់សេវា**»។

- យកចិត្តទុកដាក់គិតគូរទៅលើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋជាធំ យល់ច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួនដែលត្រូវបំពេញដើម្បីផលប្រយោជន៍រួម និងពង្រឹងសមត្ថភាពផ្ទាល់ខ្លួនឲ្យបានរឹងមាំ ដើម្បីរួមចំណែកឲ្យបានកាន់តែសកម្មក្នុងការសម្រាលទុក្ខលំបាករបស់ប្រជាពលរដ្ឋ

- **ទស្សនៈស្នូលនៃសេវាសាធារណៈ** ៖ មន្ត្រីរាជការស៊ីវិល បំពេញការងារប្រកបដោយវប្បធម៌សេវាសាធារណៈ ភក្តីភាព ឆន្ទៈម្ចាស់ការ មនសិការវិជ្ជាជីវៈនិងធ្វើឱ្យរដ្ឋបាលសាធារណៈ កាន់តែមានតម្លាភាព ភាពឆ្លើយតបប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីបម្រើប្រជាជនឱ្យកាន់តែល្អប្រសើរឡើង។

## ១. ឆន្ទៈម្ចាស់ការ Motivation

- គឺជាដំណើរការមួយដែលជំរុញ តម្រង់ទិស និងថែរក្សានូវឥរិយាបទមនុស្សទៅក្នុងទិសនៃការសម្រេចគោលបំណងណាមួយ។ កត្តាមួយដែលនាំឲ្យបុគ្គល ក្រុម ឬអង្គភាពទទួលជោគជ័យគឺកត្តាឆន្ទៈបម្រើការងាររបស់បុគ្គលនោះ ឬសមាជិកនៅក្នុងក្រុម ឬអង្គភាពនោះ

១.១. ទឹកចិត្តស្រលាញ់ការងារ

១.២. ការមានគំនិតផ្តួចផ្តើម និងច្នៃប្រឌិត

១.៣. ការបំពេញកាតព្វកិច្ចក្នុងស្មារតីជាក្រុម

១.៤. ស្មារតីឈ្នះសឈ្នះលនឹងការងារ

១.៥. ការជំម្នះឧបសគ្គ

- ឧបសគ្គខ្លះផ្តល់នូវបទពិសោធន៍កម្រសម្រាប់យើងម្នាក់ៗផងដែរ

«Challenge is Opportunity»

- មន្ត្រីរាជការត្រូវតែប្រកាន់ខ្ជាប់ដូចជា៖
  - មានស្មារតីតស៊ូអំណត់ព្យាយាម និងមិនរួញរាចំពោះភារកិច្ច
  - មានការគិតទុកជាមុន
  - មានការចែករំលែកបទពិសោធ និងចំណេះដឹងដល់អ្នករួមការងារ
  - មានការឈឺឆ្អាលចេះជួយអ្នកដទៃ
  - ការតាំងចិត្តមកធ្វើការពិតប្រាកដ   មិនមែនគ្រាន់តែមកកន្លែងធ្វើការ ហើយមិនធ្វើការ
  - មានការលះបង់ខ្ពស់ដើម្បីបុព្វហេតុរួម
  - ចាត់ទុកខ្លួនឯងជាអ្នកបម្រើប្រជាពលរដ្ឋ
  - គោរពឋានានុក្រម និងមានគណនេយ្យភាពជាដើម

## ២. ភក្តីភាព Loyalty

មន្ត្រីរាជការ ត្រូវប្រកាន់ខ្ជាប់នូវភក្តីភាពតាមរយៈសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

### ២.១. ការយល់ដឹងអំពីសភាពការណ៍

ចាំបាច់ត្រូវធ្វើការសិក្សា និងស្វែងយល់បន្ថែមនូវការវិវត្តក្នុងសង្គម និងពិភពលោក ជាពិសេសការវិវត្តរីកចម្រើនរបស់រាជរដ្ឋាភិបាលដែលខ្លួនកំពុងបំពេញការងារ។

## ២.២. ភក្តីភាពចំពោះស្ថាប័ន

ត្រូវមានភក្តីភាពជានិច្ចចំពោះប្រទេសជាតិ ចំពោះគោលនយោបាយ និង មាគ៌ាដឹកនាំរបស់រាជរដ្ឋាភិបាល ចំពោះផលប្រយោជន៍រដ្ឋ ចំពោះថ្នាក់ដឹកនាំ និងចំពោះក្រសួងស្ថាប័នរបស់ខ្លួន ដែលត្រូវប្រកាន់ខ្ជាប់គ្រប់កាលៈទេសៈ និង គ្រប់ទីកន្លែងដែលខ្លួនបំពេញការងារ ជាគុណធម៌ដែលមន្ត្រីរាជការគ្រប់រូបត្រូវ តែប្រកាន់ខ្ជាប់

## ២.៣. ភក្តីភាពចំពោះវិជ្ជាជីវៈ

មន្ត្រីរាជការទាំងអស់ត្រូវបង្ហាញឲ្យឃើញថា ខ្លួនមានសមត្ថភាពក្នុងវិជ្ជាជីវៈ ជាជរាបក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន

## ២.៤. ភក្តីភាពចំពោះប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវា

## ៣. មនសិការវិជ្ជាជីវៈ Professionalism

សកម្មភាពសំខាន់ៗត្រូវប្រតិបត្តិ មានដូចខាងក្រោម ៖

៣.១.មន្ត្រីរាជការត្រូវប្រឹងប្រែងឱ្យអស់សមត្ថភាព ដើម្បីបំពេញការងារជាមួយនឹងមធ្យោបាយដែលមាន សំដៅធ្វើឱ្យមានការរីកចម្រើន និងមានប្រសិទ្ធិភាព

៣.២.មន្ត្រីរាជការត្រូវយកចិត្តទុកដាក់ឱ្យបានច្បាស់លាស់ក្នុងការបំពេញការងារ និងមានមនសិការធ្វើការងារដើម្បីសម្រេចលទ្ធផល ស្របតាមផែនការសកម្មភាពដែលបានគ្រោងទុក ឬសកម្មភាពការងារដែលថ្នាក់លើប្រគល់ឱ្យ

៣.៣.មន្ត្រីរាជការត្រូវប្ដេជ្ញាចិត្តធ្វើការអភិវឌ្ឍខ្លួននិងប្រើប្រាស់សមត្ថភាព ចំណេះដឹង ជំនាញ ភាពប៉ិនប្រសប់ និងចរិតលក្ខណៈរបស់ខ្លួនឱ្យបានជាអតិបរមា និងប្រកបដោយសេចក្ដីថ្លៃថ្នូរ

៣.៤.មន្ត្រីរាជការត្រូវស្និតស្នាញ ក្នុងការធ្វើការងារជាមួយមន្ត្រីរាជការដទៃទៀត និងត្រូវសម្រេចលទ្ធផលការងារជាមួយគ្នានោះឱ្យបានត្រឹមត្រូវ

៣.៥.មន្ត្រីរាជការត្រូវហ៊ានលះបង់កម្លាំងកាយ និងចិត្តចំពោះការងារដែលមានជំនាញខ្ពស់ និងប្ដេជ្ញាចិត្តបម្រើប្រយោជន៍សាធារណៈ

៣.៦.មន្ត្រីរាជការចាំបាច់ត្រូវបង្កើនសមត្ថភាពជំនាញឯកទេស ចំណេះដឹង និងបទពិសោធរបស់ខ្លួន ដើម្បីអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនឲ្យទាន់សភាពការណ៍ជារៀងរហូត

៣.៧.មន្ត្រីរាជការមិនអាចយកពេលវេលាបំពេញការងារ ទៅប្រកបវិជ្ជាជីវៈឯកជនបន្ថែមដើម្បីយកកម្រៃបានទេ ទោះជាក្នុងប្រភេទណាក៏ដោយ គឺអាចធ្វើបានតែក្នុងករណីដែលច្បាប់អនុញ្ញាតប៉ុណ្ណោះ

៣.៨.មន្ត្រីរាជការមិនអាចទទួលយកដោយផ្ទាល់ ឬដោយប្រយោលតាមរយៈតំណាងរបស់ខ្លួននូវផលប្រយោជន៍នានា ពីនរណាមួយ ឬពីសហគ្រាសមួយដែលស្ថិតនៅក្រោមការត្រួតពិនិត្យរដ្ឋបាលរបស់អង្គភាពដែលខ្លួនធ្វើការ ឬអង្គភាពដែលខ្លួនមានទំនាក់ទំនង ជាមួយនោះបានទេ បើផលប្រយោជន៍នោះធ្វើឲ្យប៉ះពាល់ដល់អព្យាក្រឹតភាពរបស់មន្ត្រីរាជការ

**៣.៩.**មន្ត្រីរាជការត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈ តាមគោលការណ៍ និងស្មារតីដូចមានចែងក្នុងច្បាប់ជាធរមាន។ ឧទាហរណ៍ គ្រូពេទ្យមិនត្រូវយកស្ថានភាពរបស់អ្នកជម្ងឺម្នាក់ ទៅលាតត្រដាងប្រាប់អ្នកដទៃ គណៈមេប្រយោគមិនត្រូវធ្វើឲ្យបែកធ្លាយនូវវិញ្ញាសាសម្រាប់ការប្រឡងឡើយ ។ល។

**៣.១០.**មន្ត្រីរាជការត្រូវប្រកាន់ខ្ជាប់នូវ **កាតព្វកិច្ចលក្ខណ៍ការណ៍** មានន័យថាមិននិយាយ ឬសរសេរពីអ្វីដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងកិត្យានុភាពរបស់អង្គភាព ឬសមត្ថកិច្ចថ្នាក់ដឹកនាំរបស់ខ្លួន

**៣.១១.**មន្ត្រីរាជការ ទោះជាស្ថិតក្នុងតួនាទី ឬឋានានុក្រមណាក៏ដោយ ត្រូវតែទទួលខុសត្រូវលើការប្រតិបត្តិរបស់ខ្លួន ចំពោះភារកិច្ចដែលបានប្រគល់ឲ្យ

**៣.១២.**មន្ត្រីរាជការមានកាតព្វកិច្ចរ៉ាប់រងសេវារបស់ខ្លួនទៅតាមការចាត់តាំងរបស់ថ្នាក់លើ ចៀសវាងការចន្លោះប្រហោងនៅក្នុងការបំពេញមុខងាររបស់ខ្លួនដែលនាំឲ្យមានការផ្អាកផ្អាកនៅក្នុងវិជ្ជាជីវៈជាមន្ត្រីរាជការបម្រើរដ្ឋ

**៣.១៣.**មន្ត្រីរាជការមានកាតព្វកិច្ចគោរពវិន័យការងារ ម៉ោងពេលធ្វើការ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គភាពឲ្យបានម៉ឺងមាត់ ដើម្បីធានានិរន្តភាពនៃសេវាសាធារណៈ

**៣.១៤.**មន្ត្រីរាជការទាំងអស់ត្រូវតែគោរពបញ្ជារបស់ថ្នាក់លើ ដែលបានចាត់ឲ្យទៅបម្រើការងារ ទោះនៅទីណាក្តី

**៣.១៥.**រដ្ឋបាលសាធារណៈ គឺជារដ្ឋបាលឋានានុក្រម តម្រូវឲ្យថ្នាក់ក្រោមគោរពថ្នាក់ លើជាហូរហែតាមលំដាប់ថ្នាក់

## ៤. វប្បធម៌សេវាសាធារណៈ Service Culture

- មន្ត្រីរាជការគ្រប់រូបត្រូវតែបណ្តុះនូវវប្បធម៌សេវាសាធារណៈ ឲ្យបានដក់ជាប់ក្នុងផ្នត់គំនិតរបស់ខ្លួន ដើម្បីក្លាយទៅជាទម្លាប់ដូចការអនុវត្តនៅក្នុងវិស័យឯកជន
- «អតិថិជនជាស្តេច» ហើយ «ការពេញចិត្តរបស់អតិថិជន គឺជាភារកិច្ចរបស់គេ»
- ប្រែក្លាយខ្លួនឲ្យទៅជា «អ្នកផ្តល់សេវាដ៏មានប្រសិទ្ធិភាព»
- វប្បធម៌សេវាសាធារណៈ ផ្តោតលើគោលការណ៍មួយចំនួនដូចខាងក្រោម៖

**៤.១.ការផ្លាស់ប្តូរឥរិយាបថ**

**៤.២.អ្នកផ្តល់សេវា**

ផ្តោតទៅលើសេចក្តីត្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់សេវា

**៤.៣.អ្នកប្រឹក្សាយោបល់**

ផ្តល់ព័ត៌មាន និងពន្យល់ឲ្យបានច្បាស់ដល់ប្រជាពលរដ្ឋ អំពីនីតិវិធី របៀបរបប និងបែបបទផ្សេងៗនៃការផ្តល់សេវាសាធារណៈ

## ៤.៤.ការសម្របសម្រួល

- សីលធម៌វិជ្ជាជីវៈ មន្ត្រីរាជការទាំងអស់សុទ្ធតែស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់និងបទប្បញ្ញត្តិផ្សេងៗរៀងៗខ្លួន។ដើម្បីបំពេញវិជ្ជាជីវៈអោយបានល្អមន្ត្រីរាជការគ្រប់រូបត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវកាតព្វកិច្ចនានា
- ការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈនិងការទទួលខុសត្រូវអំពីកិច្ចការរបស់ខ្លួន
- មន្ត្រីរាជការត្រូវយកចិត្តទុកដាក់ឱ្យបានច្បាស់លាស់ក្នុងការបំពេញការងារនិងមានមនសិការ
- មន្ត្រីរាជការត្រូវប្តេជ្ញាចិត្តធ្វើការអភិវឌ្ឍខ្លួននិងប្រើប្រាស់សមត្ថភាពចំណេះដឹងជំនាញភាពប៉ិនប្រសប់និងចរិតលក្ខណៈរបស់ខ្លួននិងប្រកបដោយសេចក្តីថ្លៃថ្នូរ។

# ការដាក់ទណ្ឌកម្ម វិន័យ Disciplinary Punishment

## ❑ ការដាក់ទណ្ឌកម្ម Punishment

ទណ្ឌកម្មខាងវិន័យមានពីរថ្នាក់ គឺ ៖

**ក. ទណ្ឌកម្មថ្នាក់ទី ១ ៖** ស្តីបន្ទោស ស្តីបន្ទោសដោយមានចំណារ ក្នុងសំណុំលិខិតផ្ទាល់ខ្លួនផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬ ថ្នាក់។

**ខ. ទណ្ឌកម្មថ្នាក់ទី ២** ៖ ស្តីបន្ទោសជាទំងន់បណ្តាលអោយលុបចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ ប្រសិនជាចុះឈ្មោះហើយ ឬធ្វើអោយយឺតក្នុងការឡើងឋានន្តរស័ក្តិ ឬថ្នាក់ក្នុងថេរវេលាមួយមានកំណត់ តែមិនត្រូវអោយលើសពី២ឆ្នាំ ក្នុងការតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ តាមវេនជ្រើសរើស ឬ តាមវេនអតីតភាព។ ដាក់ឱ្យនៅទំនេរគ្មានបៀវត្សមិនអោយលើសពី១ឆ្នាំ។ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ឬបញ្ឈប់ពីការងារដោយបង្ខំ។ បណ្តេញចេញពីមុខតំណែងរាជការ ។

# ❑ កំហុសខាងវិន័យ Disciplinary Action

- កំហុសខាងវិន័យ គឺជាកំហុសកើតឡើងពីការប្រព្រឹត្តដោយចេតនា ឬអចេតនា ការខកខាន មិនបានប្រព្រឹត្ត ការភ្លេចភ្លាំង ការធ្វេសប្រហែស ការខ្ជីខ្ជានិងរាល់ការបំពានទៅលើជំពូក៥ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ចំពោះមាត្រា ៣៣ ៣៤ ៣៥ ៣៧ ៣៨ ៣៩ ដែលកំណត់តាមអំណាចឆន្ទានុសិទ្ធិរបស់

អាជ្ញាធរដាក់វិន័យថា ជាការខ្វះខាតក្នុងការបំពេញការតព្វកិច្ច។

- រាល់កំហុសវិន័យដែលប្រព្រឹត្តដោយមន្ត្រីរាជការតម្រូវឱ្យទទួលទណ្ឌកម្មខាងវិន័យ។ កំហុសខាងវិន័យកំហុសខាងរដ្ឋប្បវេណី និងកំហុសខាងព្រហ្មទណ្ឌមានស្វយ័តភាពរវាងគ្នា។ទណ្ឌកម្មវិន័យនិងទណ្ឌកម្មព្រហ្មទណ្ឌក៏មានស្វយ័តភាពរវាងគ្នាដែរ។
- ពាក់ព័ន្ធនឹងវិន័យ គឺអ្នករាជការរាល់រូបត្រូវទទួលទណ្ឌកម្មខាងវិន័យដែលមាន ២ថ្នាក់ ក្នុងករណីដែលបានប្រព្រឹត្តកំហុសនិងការផ្តាំផ្តងខាងវិន័យ។

## ❑ ការចូលនិវត្តន៍ Retirement

➢ គឺជាដំណាក់កាលចុងក្រោយនៃជីវិតការងាររបស់មន្ត្រីរាជការនៅក្នុងអាជីពរបស់ខ្លួន ។

**ការចូលនិវត្តន៍ដោយការដល់អាយុកំណត់អោយចូលនិវត្តន៍**

(អាស្រ័យតាមប្រភេទក្របខ័ណ្ឌ និងឋានន្តរស័ក្តិ ឬមុខតំណែង)

✓ មន្ត្រីក្របខ័ណ្ឌប្រភេទ "ក" (អាយុ៦0ឆ្នាំ)

- ក៣ ប្រកាស
- ក២ អនុក្រឹត្យ
- ក១ ព្រះរាជក្រឹត្យ

## ❑ ការចូលនិវត្តន៍មុនអាយុចូលនិវត្តន៍ Vuluntary Retirement

- មន្ត្រីរាជការនៃវិស័យសាធារណៈ ដែលបានបម្រើការងារអស់រយៈពេលយ៉ាងតិច ៣០ (សាមសិប)ឆ្នាំ មានសិទ្ធិស្នើសុំចូលនិវត្តន៍មុនអាយុ ចូលនិវត្តន៍៦០ (ហុកសិប)ឆ្នាំ ដោយទទួលបានប្រាក់សោធនដែលត្រូវកំណត់ដោយព្រះរាជក្រឹត្យ។
- សិទ្ធិស្នើសុំចូលនិវត្តន៍មុនអាយុចូលនិវត្តន៍មានសុពលភាពអនុវត្តក្នុងរយៈពេល៥ (ប្រាំ)ឆ្នាំ បន្ទាប់ពីព្រះរាជក្រឹត្យស្ដីពីលក្ខខណ្ឌ បែបបទនិងនីតិវិធី នៃការអនុវត្តផ្នែកប្រាក់សោធនសម្រាប់មន្ត្រីរាជការនៃវិស័យសាធារណៈចូលជាធរមាន។

❑ **ការដាក់ឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ**

Placement on Disability Pension

- មន្ត្រីបាត់បង់សម្បទាវិជ្ជាជីវៈ +អតីតភាពការងារចាប់ពី២០ឆ្នាំ⇨ក្រោម៣០ឆ្នាំ

  + មិនគ្រប់អាយុចូលនិវត្តន៍

- ប្រភេទនៃការបាត់បង់សម្បទាវិជ្ជាជីវៈ
  - ✓ ដោយគ្រោះថ្នាក់ការងារ :
    - ➢ គ្រោះថ្នាក់ដែលកើតក្នុងពេលធ្វើការជូនក្រសួង( មូលហេតុណាក៏ដោយ/ មានឬគ្មានកំហុសអ្នករាជការ) ➡ បាត់បង់វិជ្ជាជីវៈទាំងស្រុងនិងអចិន្ត្រៃយ៍ :

- រៀបចំសំភារៈ ពលកម្ម ឬម៉ាស៊ីន ។

-បំពេញសេចក្តីត្រូវការផ្ទាល់ខ្លួនៈហូបចុក /បំបៅកូន/សំអាតខ្លួនក្រោយធ្វើការ

គ្រោះថ្នាក់ការងារក្នុងពេលបេសកកម្ម

- ➢ បញ្ចេញនូវវីរភាពក្នុងការបំពេញបេសកកម្មអង្គភាពប្រគល់អោយ

  + បានលះបង់ជីវិតរបស់ខ្លួន

- ➢ ការពារទ្រព្យសម្បត្តិរដ្ឋ ឬសាធារណៈ ៈ ភ្លើងឆេះផ្ទះ ទឹកជំនន់ ។ល។

ជំងឺ ឬគ្រោះថ្នាក់ផ្សេងៗៈ

- ➢ គ្រោះថ្នាក់ផ្សេងៗ ក្រៅពីករណីគ្រោះថ្នាក់ការងារខាងលើ

# អ្វីទៅជាការគ្រប់គ្រងធនធានមនុស្ស?

- គឺជាដំណើរការនៃការវាយតម្លៃអំពីតម្រូវការធនធានមនុស្ស ការកំណត់ធនធានមនុស្សដើម្បីបំពេញតម្រូវការនោះ និងទទួលលទ្ធលការងារដ៏ធំបំផុតពីនិយោជិយម្នាក់ៗ
- គឺសំដៅដល់មនុស្ស/បុគ្គលិកដែលបំរើការងារក្នុងអង្គភាព/ស្ថាប័ន ជាទូទៅសំដៅលើមនុស្សដែលមានសមត្ថភាព ជំនាញ និងបទពិសោធន៍បំពេញការងារ
- មន្រ្តីរាជការស៊ីវិល ដែលមានសមត្ថភាព វិជ្ជាជីវៈច្បាស់លាស់ និងប្រសិទ្ធភាពបំពេញការងារ *(គោលនយោបាយធនធានមនុស្ស)*

# គោលនយោបាយធនធានមនុស្ស

- **ចក្ខុវិស័យ និងគោលបំណង៖**
  - មន្ត្រីរាជការកាន់តែមានសមត្ថភាព ភាពស្វាហាប់ ប្រសិទ្ធភាព និងការជឿទុកចិត្តក្នុងការផ្តល់សេវាសាធារណៈ តាមរយៈ វប្បធម៌សេវាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និង មនសិការវិជ្ជាជីវៈ ហើយត្រូវចាត់ចែងឱ្យបំពេញការងារដោយផ្តោតលើតម្រូវការជាក់ស្តែងប្រកបដោយប្រសិទ្ធភាពខ្ពស់



ឆន្ទៈម្ចាស់ការ

វប្បធម៌
សេវាសាធារណៈ

?

ភក្តីភាព

មនសិការវិជ្ជាជីវៈ

# វប្បធម៌សេវាសាធារណៈ

ជាការផ្លាស់ប្តូរទស្សនវិស័យទៅជា "អ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព" ដោយចាត់ទុក "អតិថិជនជាស្តេច" រួមមាន៖

- ការផ្លាស់ប្តូរឥរិយាបថ (ពីអ្នកត្រួតត្រា ទៅជា អ្នកផ្តល់សេវា)
- អ្នកផ្តល់សេវា (ផ្តល់ជំនឿទុកចិត្ត ភាពកក់ក្តៅ ភាពរាក់ទាក់ និងការគោរព)
- អ្នកប្រឹក្សាយោបល់ (ផ្តល់ព័ត៌មាន និងពន្យល់នីតិវិធី របៀបរបប និងបែបបទផ្តល់សេវា)
- ការសម្របសម្រួល (កាត់បន្ថយនិងធ្វើឱ្យសាមញ្ញនីតិវិធីនិងពេលវេលាផ្តល់សេវា)
- សេវាសាធារណៈប្រកបដោយគុណភាព មានភាពសាមញ្ញ ប្រសិទ្ធភាព អាចជឿទុកចិត្តបាន

ឆាប់រហ័ស ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការ មានភាពងាយស្រួល និងមានការចូលរួមពីអ្នកប្រើប្រាស់សេវា។

# ឆន្ទៈម្ចាស់ការ

- គឺជាដំណើរការជំរុញ តម្រង់ទិស និងរក្សាឥរិយាបថមនុស្សក្នុងការសម្រេចគោលបំណងណាមួយ
- ជាឆន្ទៈបម្រើការងាររបស់បុគ្គល/ក្រុម/អង្គភាព ដែលផ្តើមចេញពីមនសិការខាងក្នុងរបស់មនុស្ស ដោយផ្សារភ្ជាប់នឹងការងារ និងរបៀបនៃការប្រតិបត្ត រួមមាន ៖
  - ទឹកចិត្តស្រឡាញ់ការងារ (មកធ្វើការ ព្យាយាមធ្វើការ ផ្លាស់ប្តូរបទពិសោធន៍ ពង្រឹងសមត្ថភាព)
  - មានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត (កែលម្អសកម្មភាពការងារ ដើម្បីប្រសិទ្ធភាព និងជោគជ័យ)
  - បំពេញកាតព្វកិច្ចក្នុងស្មារតីជាក្រុម (ការចូលរួម និងសម្រេចគោលដៅរួម)
  - ស្មារតីឈ្នះឈ្នុលនឹងការងារ (មិនចាំការងាររត់មករក ពង្រឹងចំណេះដឹងចំណេះធ្វើ)
  - ជម្នះឧបសគ្គ (ស្មារតីទទួលខុសត្រូវ)

# ភក្តីភាព

សំដៅ សីលធម៌និងសុជីវធម៌ ជាគុណតម្លៃខាងចរិយាធម៌របស់មនុស្ស ជាសកម្មភាពនិងការទទួលខុសត្រូវ ដើម្បីផលប្រយោជន៍អង្គភាពនិងសាធារណៈ

រួមមាន៖

- ការយល់ដឹងអំពីសភាពការណ៍ (សិក្សានិងស្វែងយល់សភាពការណ៍វិវត្តសង្គមពិភពលោក និងពិសេសការរីកចម្រើនរបស់រាជរដ្ឋាភិបាល)
- ភក្តីភាពចំពោះស្ថាប័ន (ស្មោះត្រង់ចំពោះថ្នាក់ដឹកនាំនិងស្ថាប័នខ្លួន ចំពោះរាជរដ្ឋាភិបាល និងផលប្រយោជន៍រួម ដែលជាគុណធម៌របស់មន្ត្រី)
- ភក្តីភាពចំពោះវិជ្ជាជីវៈ (គោរពការសម្ងាត់វិជ្ជាជីវៈ ការទទួលខុសត្រូវ សមត្ថភាពក្នុងវិជ្ជាជីវៈ)
- ភក្តីភាពចំពោះប្រជាពលរដ្ឋ/អ្នកប្រើប្រាស់សេវា (អនុវត្តការងារតាមការបែងចែកនិងការកំណត់ភារកិច្ច វត្តមានការងារ ប្រជាពលរដ្ឋជាអតិថិជន)។

# មនសិការវិជ្ជាជីវៈ

ការអនុវត្តការងារដោយគោរពកាតព្វកិច្ចដែលកំណត់ក្នុងច្បាប់និងបទប្បញ្ញត្តិនានា ដោយលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈនិងការទទួលខុសត្រូវ ដើម្បីប្រសិទ្ធភាពការងារ

រួមមាន៖

- ប្រឹងប្រែងបំពេញការងារឱ្យអស់លទ្ធភាពតាមមធ្យោបាយដែលមាន
- បំពេញការងារដើម្បីសម្រេចលទ្ធផល ស្របតាមផែនការសកម្មភាពគ្រោង និងថ្នាក់លើប្រគល់ឱ្យ
- អភិវឌ្ឍសមត្ថភាព ចំណេះដឹង ជំនាញ
- សហការការងារជាមួយមន្ត្រីរាជការដទៃដើម្បីសម្រេចលទ្ធផលរួម
- លះបង់កម្លាំងកាយនិងចិត្តបំពេញការងារដើម្បីបំរើផលប្រយោជន៍សាធារណៈ
- រក្សាការសម្ងាត់វិជ្ជាជីវៈ
- គោរពកាតព្វកិច្ចលក្ខណការណ៍
- គោរពវិន័យការងារ ម៉ោងពេលធ្វើការ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គភាព
- គោរពឋានានុក្រមការងារ ដើម្បីប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវ

«បម្រើ
ប្រជាជន
ឲ្យបានកាន់តែ
ល្អប្រសើរឡើង »




## គោលដៅ

១-កែលម្អរបៀបរបបគ្រប់គ្រងការចាត់ចែងការងារ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ពីតួនាទីនិងភារកិច្ចនិងពីតម្រូវការធនធានមនុស្ស ទាំងបរិមាណ និងគុណភាព ដោយផ្អែកលើទំហំការងារ

២-ពង្រឹងការគ្រប់គ្រងជំនាញនិងចំនួនមន្ត្រី (Personnel management) តាមតម្រូវការ

៣-លើកកម្ពស់គុណផល (Performance) និងការទទួលខុសត្រូវរបស់មន្ត្រី

៤-អភិវឌ្ឍសមត្ថភាពការងាររបស់មន្ត្រីរាជការ

៥-ពង្រឹងសីលធម៌និងវិន័យមន្ត្រីរាជការ



- ការពង្រឹងសមត្ថភាពគ្រប់គ្រងរដ្ឋបាលក្រសួង ស្ថាប័ន
- ពង្រាយតម្លាភាពក្នុងដំណើរការនៃការបង្កើនគុណភាពសេវាសាធារណៈ
- អភិវឌ្ឍន៍ធនធានមនុស្សនិងស្ថាប័ន
- ពង្រឹងគណនេយ្យភាពក្នុងការបង្កើនប្រសិទ្ធភាពសេវាសាធារណៈ
- អភិវឌ្ឍន៍ការគ្រប់គ្រងក្របខ័ណ្ឌ
- ពង្រាយមន្ត្រីរាជការ
- ការជម្រុញរៀនភាសាអង់គ្លេស
- ការជម្រុញប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ការគ្រប់គ្រងនិងអភិវឌ្ឍន៍មន្ត្រីរាជការស៊ីវិលឱ្យកាន់តែមានសមត្ថភាព ភាពស្វាហាប់ប្រសិទ្ធភាព និងភាពជឿទុកចិត្តបាន
- ប្រព័ន្ធបៀវត្សដែលធានាបាននូវសមធម៌ ប្រសិទ្ធភាពការងារ ព្រមទាំងធានាបាននូវសង្គតិភាពក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ។

«បម្រើ

ប្រជាជន

ឲ្យបានកាន់តែ

ល្អប្រសើរឡើង »

# យុទ្ធសាស្ត្រ

១-ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធការងារក្នុងអង្គភាព និងការគ្រប់គ្រងមន្ត្រី។

២-ពង្រឹងប្រសិទ្ធភាពនៃដំណើរការអនុវត្តការគ្រប់គ្រងធនធានមនុស្ស។

៣-អនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល។

៤-ប្រើប្រាស់ឱ្យកាន់តែប្រសើរឡើងនូវសមត្ថភាពការងារដែលមានស្រាប់ និងអភិវឌ្ឍសមត្ថភាពការងារថ្មី។

៥-ផ្តល់ការបណ្តុះបណ្តាល និងលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល។



# ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស

- ❖ រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគតិយុត្ត នៃការបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល និងកែលម្អកម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សនៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ❖ រៀបចំអង្គមន្ត្រីរាជការស៊ីវិល មុខតំណែង និងការពិពណ៌នាមុខតំណែងក្នុងមុខងារសាធារណៈ
- ❖ រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្តនៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ❖ កែលម្អរចនាសម្ព័ន្ធគ្រប់គ្រង បែបបទការងារ និងការអភិវឌ្ឍសមត្ថភាពរបស់នាយកដ្ឋាន ឬអង្គភាពធនធានមនុស្សនៅតាមក្រសួង ស្ថាប័ន

# ទស្សនៈទាននៃការគ្រប់គ្រងធនធានមនុស្ស

- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធការងាររបស់អង្គភាព និងការគ្រប់គ្រងមន្ត្រី។
- លើកកម្ពស់ប្រសិទ្ធការងារនិងស្មារតីទទួលខុសត្រូវក្នុងរដ្ឋបាលសាធារណៈ។
- ពង្រឹងប្រសិទ្ធភាពនៃដំណើរការអនុវត្តការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស។
- ប្រើប្រាស់ឱ្យកាន់តែប្រសើរឡើងនូវសមត្ថភាពការងារថ្មី។
- ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។
- កែលំអរបៀបរបបគ្រប់គ្រងការងារតាមរយៈការរៀបចំប្រព័ន្ធការងារច្បាស់លាស់ ការកំណត់សមត្ថភាពការងាររបស់មុខតំណែងសំខាន់ៗតាមរយៈការរៀបចំការពិពណ៌នាមុខតំណែង និងការកំណត់ចំនួនមន្ត្រីឲ្យបានសមស្របប្រកបដោយគុណភាពទៅតាមទំហំការងារ។

- កែលម្អនីតិវិធី និងបែបបទនៃការគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ធ្វើការវិភាគមុខងារ និងត្រួតពិនិត្យប្រតិបត្តិការឡើងវិញនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- អភិវឌ្ឍ និងពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្សនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

# ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធការងាររបស់អង្គភាព និង ការគ្រប់គ្រងមន្ត្រី

- ប្រគល់ភារកិច្ចនិងផ្តល់សិទ្ធិទទួលខុសត្រូវការងារទៅតាមមុខតំណែងឱ្យបានសមស្រប
- បែងចែកការងារទៅដល់មន្ត្រីតាមសមត្ថភាពនិងជំនាញ
- វាយតម្លៃជាទៀងទាត់ចំពោះរាល់ការអនុវត្តការងាររបស់មន្ត្រីដោយផ្អែកលើផែនការការងារ

# លើកកម្ពស់ប្រសិទ្ធភាពការងារនិងស្មារតីទទួលខុសត្រូវនៅក្នុងរដ្ឋបាលសាធារណៈ

- អនុវត្តប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារតាមរយៈការប្រើប្រាស់ការពិពណ៌នាមុខតំណែងសម្រាប់បែងចែកការទទួលខុសត្រូវឲ្យបានច្បាស់លាស់ដល់មន្ត្រីម្នាក់ៗ
- ជ្រើសរើសមន្ត្រីឲ្យបានសមស្រប ត្រឹមត្រូវ និងមានតម្លាភាពទៅតាមមុខតំណែងដែលត្រូវការ ដោយផ្អែកលើលក្ខណៈសម្បត្តិសក្តិសម

# ពង្រឹងប្រសិទ្ធភាពនៃដំណើរការអនុវត្តការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

- ពិនិត្យឡើងវិញនិងការកែលម្អរាល់ដំណើរការនៃការគ្រប់គ្រងនិងការអភិវឌ្ឍធន ធានមនុស្សរបស់ក្រសួង ស្ថាប័ន ឱ្យមានប្រសិទ្ធភាព
- ជំរុញការអនុវត្តរាល់បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការអភិវឌ្ឍ ធនធានមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។

# ប្រើប្រាស់ឲ្យកាន់តែប្រសើរឡើងនូវសមត្ថភាពការងារ ដែលមានស្រាប់និងអភិវឌ្ឍសមត្ថភាពការងារថ្មី

- រៀបចំឲ្យមានយន្តការគ្រប់គ្រងអ្នកមានទេពកោសល្យនិងការធ្វើផែនការអាជីព
- វាយតម្លៃនិងវិភាគទៅលើតម្រូវការបណ្តុះបណ្តាល ព្រមទាំងរៀបចំ និង អនុវត្តកម្មវិធីសិក្សាសម្រាប់មន្ត្រីដើម្បីឆ្លើយតបនឹងតម្រូវការ។

# ផ្តល់ការបណ្តុះបណ្តាលនិងលើកកម្ពស់គុណភាពការបណ្តុះបណ្តាល

- អភិវឌ្ឍសមត្ថភាពស្ថាប័នផ្តល់សេវាបណ្តុះបណ្តាលរបស់ស្ថាប័នរដ្ឋ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

# អភិវឌ្ឍសមត្ថភាពដើម្បីគ្រប់គ្រងធនធានមនុស្ស និងប្រសិទ្ធភាពការងារ

- ធ្វើផែនការ សម្របសម្រួល និងបណ្តុះបណ្តាលជំនាញគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សសម្រាប់អ្នកគ្រប់គ្រង និងមន្ត្រីអង្គភាពធនធានមនុស្ស
- ធ្វើការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពមន្ត្រីអង្គភាពធនធានមនុស្ស។

# ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

- ក្រសួងមុខងារសាធារណៈ រៀបចំត្រួតពិនិត្យឡើងវិញជារៀងរាល់ឆ្នាំនូវការអនុវត្តផែនការសកម្មភាពដែលបានកំណត់សម្រាប់ ការអនុវត្តគោលនយោបាយធនធានមនុស្ស ដោយប្រើប្រាស់សូចនាករដែលផ្តោតលើគុណភាពនិងបរិមាណ ដើម្បីធានាថាគោលដៅទាំងអស់ត្រូវបានសម្រេច។

- ការតាមដាននិងការវាយតម្លៃនឹងត្រូវបានចែកជូនសមាជិករបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រសួង ស្ថាប័ន និងមន្ត្រីនៅផ្នែកធនធានមនុស្សសម្រាប់ធ្វើការពិនិត្យនិងកែលម្អការអនុវត្ត។ លទ្ធផលទទួលបានពីការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ និងមេរៀនបទពិសោធន៍នឹងត្រូវប្រើប្រាស់សម្រាប់ការពង្រឹង ការអនុវត្តគោលនយោបាយនេះ។

# ការគ្រប់គ្រងគុណផល

- **គុណផល៖** សំដៅដល់ទង្វើ និង របៀបរបបអនុវត្តការងាររបស់មន្ត្រីរាជការ ដើម្បីទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាព។
- **ការគ្រប់គ្រងគុណផល៖**
  - ជាផ្នែកមួយនៃ**ការគ្រប់គ្រងដោយផ្អែកលើលទ្ធផលការងារ**
  - ជាដំណើរការនៃការគ្រប់គ្រងការបំពេញការងាររបស់មន្ត្រីរាជការ ដោយផ្អែកតាមប្រព័ន្ធគ្រប់គ្រងគុណផល ដើម្បីជំរុញឱ្យមន្ត្រី និង អ្នកគ្រប់គ្រង មានការទទួលខុសត្រូវ មានការចូលរួម និង បំពេញការងារឱ្យអស់ពីសមត្ថភាពរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និង ការអភិវឌ្ឍសមត្ថភាព។

- **ប្រព័ន្ធគ្រប់គ្រងគុណផល៖** ជាអភិក្រមនៃការគ្រប់គ្រងគុណផលរបស់មន្ត្រីរាជការ និងអ្នកគ្រប់គ្រងរបស់អង្គភាព ឬ ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់យន្តការជាប្រព័ន្ធ និងមានសមាសធាតុសំខាន់ៗ ដែលរួមមាន៖

- ផែនការការងារប្រចាំឆ្នាំ
- ការពិពណ៌នាមុខតំណែង
- ល័ក្ខខ័ណ្ឌការងារ
- ការត្រួតពិនិត្យវត្តមាន
- រំហូររបាយការណ៍ និង
- អភិក្រមនៃការត្រួតពិនិត្យឡើងវិញ និងការវាយតម្លៃ

ដើម្បីបង្កើនសមត្ថភាព និងផលិតភាពការងារ និងឈានទៅសម្រេចឱ្យបាន ជោគជ័យនូវគោលដៅ និង លទ្ធផលរំពឹងទុករបស់អង្គភាព ឬ ក្រសួងស្ថាប័ន។

# 1.គោលបំណងនិងគោលដៅនៃប្រព័ន្ធគ្រប់គ្រងគុណផល

- គោលបំណង៖ លើកកម្ពស់ប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព និង បង្កើនសមត្ថភាព និង ផលិតភាពការងារ សំដៅសម្រេចឱ្យបានជោគជ័យនូវគោលដៅ និង លទ្ធផលរំពឹងទុក របស់អង្គភាព និង ក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- គោលដៅ៖
  - កំណត់អំពីផែនការប្រចាំឆ្នាំរបស់អង្គភាព
  - សម្រេចឱ្យបាននូវការងារអាទិភាពរបស់ក្រសួងស្ថាប័ន
  - បង្កើនប្រសិទ្ធភាពនិងផលិតភាពការងាររបស់មន្ត្រីម្នាក់ៗនិងអង្គភាព
  - ជំរុញឱ្យមន្ត្រីម្នាក់ៗបំពេញការងារឱ្យអស់ពីសមត្ថភាពរបស់ខ្លួន
  - បង្កើតវេទិកាពិភាក្សារវាងអ្នកគ្រប់គ្រងផ្ទាល់ជាមួយនឹងមន្ត្រីអំពីល័ក្ខខ័ណ្ឌការងារ និង គុណផល
  - ផ្តល់ការលើកទឹកចិត្ត និង រង្វាន់ដល់មន្ត្រី និង អង្គភាពដែលមានគុណផលឆ្នើម
  - កំណត់ពីតម្រូវការជាក់ស្តែងក្នុងការអភិវឌ្ឍសមត្ថភាព ឬ បញ្ហាប្រឈមជាក់ស្តែងរបស់អង្គភាព នីមួយៗ។

# 2.អត្ថប្រយោជន៍នៃប្រព័ន្ធគ្រប់គ្រងគុណផល

## គោលការណ៍សាកល

- **ទី១.** ប្រើប្រាស់ជាឧបករណ៍សម្រាប់រៀបចំផែនការ គឺសម្រាប់កំណត់ទិសដៅអនាគត និងផែនការសកម្មភាពសម្រាប់អនុវត្ត។
- **ទី២.** ប្រើប្រាស់សម្រាប់ការគ្រប់គ្រង ការតាមដាន និងត្រួតពិនិត្យការអនុវត្តការងាររបស់មន្ត្រី និងអង្គភាព។
- **ទី៣.** ប្រើប្រាស់សម្រាប់ការរៀបចំថវិកាគាំទ្រដល់ការអនុវត្តការងាររបស់មន្ត្រីនិងអង្គភាព។
- **ទី៤.** លើកកម្ពស់គុណតម្លៃខាងសេដ្ឋកិច្ច ដូចជា ភាពស័ក្តិសិទ្ធ ប្រសិទ្ធិភាព និងផលិតភាពនៃការបង្កើនគុណផលការងារ។
- **ទី៥.** លើកកម្ពស់គុណតម្លៃខាងប្រជាធិបតេយ្យ តាមរយៈការចូលរួមពិភាក្សាលើផែនការរួមរវាងថ្នាក់ដឹកនាំនិងមន្ត្រី ព្រមទាំងផ្តល់តម្លាភាពចំពោះការវាយតម្លៃលើគុណផល។
- **ទី៦.** លើកកម្ពស់គុណតម្លៃនៃភាពត្រឹមត្រូវ តាមរយៈការផ្សាភ្ជាប់គោលបំណង និង បេសកកម្មរបស់មន្ត្រី និង អង្គភាពទៅនឹងចក្ខុវិស័យជាយុទ្ធសាស្ត្ររបស់អង្គភាព និង ក្រសួងស្ថាប័ន។

# 3.គោលការណ៍រួមសម្រាប់ការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល

- **បរិយាកាសឬវប្បធម៌នៃស្ថាប័ន:**
  - ការគ្រប់គ្រងផ្តោតលើលទ្ធផល
  - ការទទួលខុសត្រូវ
  - ការប្តេជ្ញាចិត្តខ្ពស់របស់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន អង្គភាព
  - ឥរិយាបថគំរូក្នុងការដឹកនាំនិងការបំពេញការងារ
- **ភាពស៊ីចង្វាក់គ្នា:**
  - ផ្សារភ្ជាប់ការធ្វើផែនការការងារនិងផែនការថវិកា
  - លទ្ធផលនៃការវាយតម្លៃគុណផលរបស់មន្ត្រីផ្សារភ្ជាប់នឹងដំណើរការនៃការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស

## ❖ ការចូលរួមៈ

- ការប្រឹក្សាយោបល់ក្នុងការបង្កើតនិងកែសម្រួលផែនការរួមរបស់អង្គភាពនិងមន្ត្រី និង
- ការចូលរួមពិភាក្សាលើលទ្ធផលនៃការវាយតម្លៃ តាមរយៈការផ្តល់ការណែនាំ និងពិគ្រោះយោបល់រវាងអ្នកគ្រប់គ្រងផ្ទាល់ និងមន្ត្រី

## ❖ គុណផលៈ

- ផ្តល់ព័ត៌មានត្រឡប់លើគុណផលធៀបនឹងផែនការការងារ លទ្ធផលរំពឹងទុក និង
- បង្ហាញហេតុផលចំពោះសកម្មភាពពុំទាន់បានសម្រេចនិងបញ្ហាប្រឈម

## ❖ សមត្ថភាពអនុវត្តៈ

- តម្រូវការខាងសមត្ថភាពក្នុងការអនុវត្តដូចជាការរៀបចំផែនការ ការតាមដានត្រួតពិនិត្យវាយតម្លៃ ភាពជាអ្នកដឹកនាំ និងស្មារតីជាក្រុម។ល។

# ភាពពិពណ៌នាមុខតំណែង

ការផ្តល់ជាទស្សនវិស័យ ចំណេះដឹងបន្ថែម និងគុណវិឌ្ឍ ក្នុងការអនុវត្តន៍តួនាទី ភារកិច្ចរបស់ក្រសួង ស្ថាប័ន ដើម្បីរៀបចំការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងការធ្វើបច្ចុប្បន្នភាព រចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួង ស្ថាប័ន ត្រូវគ្រប់គ្រង និងចាត់ចែងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដោយកំនត់បានពិតប្រាកដនូវតម្រូវការធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពមន្ត្រី និងកាតពង្រាយមន្ត្រី។ ការចូលរួមដោះស្រាយបញ្ហាមួយចំនួនដែលក្រសួង ស្ថាប័ន បាននិងកំពុងជួបប្រទះ ដូចជា៖

- ភាពមិនច្បាស់លាស់ ឬការត្រួតជាន់គ្នានៃមុខងារ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ
- ភាពខ្វះចន្លោះនៃការធ្វើអាទិភាវូបនីយកម្មទៅលើសកម្មភាពដែលក្រសួង ស្ថាប័នត្រូវអនុវត្ត
- ភាពស្មុគស្មាញនៅក្នុងអន្តរទំនាក់ទំនងរវាងក្រសួង ស្ថាប័ន និងបញ្ហាអសង្គតិភាពនៃការកំណត់សមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និង
- ភាពមិនពេញចិត្តរបស់អ្នកប្រើប្រាស់សេវាចំពោះកម្រិតគុណភាព នៃសេវាដែលផ្តល់ដោយក្រសួង ស្ថាប័ន ជាដើម

- ផលប៉ះពាល់នៃការប្រើប្រាស់បច្ចេកវិទ្យាថ្មី ក្នុងការអនុវត្តមុខងារ និងសកម្មភាពការងារទាំងឡាយរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន។

- **ការពិពណ៌នាមុខតំណែង រួមមាន៖**

- ✓ កំណត់អំពីតួនាទីនិងការទទួលខុសត្រូវច្បាស់លាស់
- ✓ កំណត់អំពីការរាយការណ៍ទៅតាមមុខតំណែង
- ✓ កំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការជ្រើសរើស ការតែងតាំង និងផែនការអភិវឌ្ឍធនធានមនុស្ស៖
  - ក្របខណ្ឌឋានន្តរស័ក្តិ
  - លក្ខណៈសម្បត្តិ (កម្រិតវប្បធម៌+ជំនាញវិជ្ជាជីវៈ បទពិសោធន៍ការងារ ការបណ្តុះបណ្តាលផ្សេងៗ ជំនាញព័ត៌មានវិទ្យានិងភាសាបរទេស សមត្ថភាពបំពេញការងារ និងសមត្ថភាពវិជ្ជាជីវៈ)

# ឧបសម្ព័ន្ធ៣៖ ការពិពណ៌នាមុខតំណែង

**១. ក្រសួង ស្ថាប័ន៖**........................................................**អង្គភាព**.........................................................

**២. ឈ្មោះមុខតំណែង[1]៖**.......................................................................................................................

**៣. ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់**( មុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ )៖.........................................................

**៤. របាយការណ៍៖** ត្រូវរៀបចំរបាយការណ៍ប្រចាំខែស្តីពីការបំពេញការងាររបស់ខ្លួនជូន...........( មុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ )...............។

**៥. តួនាទីនិងការទទួលខុសត្រូវ៖** ( គឺជាបញ្ជីភារកិច្ចសំខាន់ៗដែលកំណត់ទៅតាមតួនាទីនីមួយៗដោយផ្អែកទៅតាមអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នសាមី ដែលមានកំណត់អំពីតួនាទីនិងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន/នាយកដ្ឋាន និងប្រកាសស្តីពីការបង្កើតការិយាល័យនិងអង្គភាពចំណុះថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលមានកំណត់អំពីតួនាទីនិងភារកិច្ចរបស់ការិយាល័យ និងអង្គភាពចំណុះ )

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**៦. លក្ខណៈសម្បត្តិនិងឧបនិស្ស័យតាមមុខតំណែងនីមួយៗ៖**

| **ក្របខ័ណ្ឌឋានន្តរសក្តិ**<br>*( យោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន )* | **លក្ខណៈសម្បត្តិ** | |
|---|---|---|
| | **ឧបនិស្ស័យសម្រាប់កាន់មុខតំណែង**<br>*( យោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន )* | |
| | - កម្រិតវប្បធម៌ | : ....................................................... |
| | - ជំនាញឯកទេស | : ....................................................... |
| | - បទពិសោធន៍ការងារ[2] | : ....................................................... |
| | - ការបណ្តុះបណ្តាលផ្សេងៗ[3] | : ....................................................... |
| | - ជំនាញព័ត៌មានវិទ្យា និងភាសាបរទេស( បើចាំបាច់ ) | : ....................................................... |
| | - សមត្ថភាពបំពេញការងារ[4] ៖<br>○ ការទទួលខុសត្រូវ និងវិន័យការងារ ( ឋានានុក្រម បទបញ្ជាផ្ទៃក្នុង ម៉ោងពេលធ្វើការ )<br>○ ការរៀបចំផែនការច្បាស់លាស់ និងការសម្រេចបានលទ្ធផល<br>○ ការបន្តអភិវឌ្ឍសមត្ថភាព ចំណេះដឹង និងជំនាញ<br>○ ការសហការការងារ និងស្មារតីជាក្រុម | |

| | |
|---|---|
| | ○ គោរពការសម្ងាត់វិជ្ជាជីវៈនិងកាតព្វកិច្ចលក្ខណការណ៍<br>○ គំនិតផ្តួចផ្តើម ច្នៃប្រឌិត និងកែលម្អនីតិវិធី និងរបៀបរបបការងារ |
| | - សមត្ថភាពវិជ្ជាជីវៈ[5] ៖<br>○ ...............................................................................................<br>○ ...............................................................................................<br>○ ............................................................................................... |

**កំណត់សំគាល់៖**

១. អ្នកគ្រប់គ្រងផ្ទាល់ត្រូវរៀបចំ និងបំពេញការពិពណ៌នាមុខតំណែងដោយសហការជាមួយនាយកដ្ឋានបុគ្គលិកឬអង្គភាពធនធានមនុស្សរបស់ខ្លួន។

២. ការពិពណ៌នាមុខតំណែង( ដូចជា អគ្គលេខាធិការ/អគ្គនាយក/ប្រធានមន្ទីរជំនាញ ) ត្រូវអនុម័តដោយរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី។

៣. ការពិពណ៌នាមុខតំណែងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃលេខ០៣៨.សណន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការរៀបចំល័ក្ខខ័ណ្ឌការងារសម្រាប់មន្ត្រី បុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ៦. លក្ខណៈសម្បត្តិនិងឧបនិស្ស័យតាមមុខតំណែងនីមួយៗ៖

| ក្របខណ្ឌឋានន្តរស័ក្តិ *(យោងតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន)* | លក្ខណៈសម្បត្តិ<br>ឧបនិស្ស័យសម្រាប់កាន់មុខតំណែង *(យោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន)* | |
|---|---|---|
| | - កម្រិតវប្បធម៌ | : ........................................................ |
| | - ជំនាញវិជ្ជាជីវៈ | : ........................................................ |
| | - បទពិសោធន៍ការងារ[2] | : ........................................................ |
| | - ការបណ្ដុះបណ្ដាលផ្សេងៗ[3] | : ........................................................ |
| | - ជំនាញព័ត៌មានវិទ្យា និង ភាសាបរទេស(បើចាំបាច់) | : ........................................................ |

1. បទពិសោធន៍ការងារៈ

១. (ការងារដឹកនាំ គ្រប់គ្រង ចាត់ចែង សម្របសម្រួល) ចំពោះអគ្គនាយក (រយៈពេលបំពេញការងារចាប់ពី ១៣ឆ្នាំឡើង) ចំពោះអគ្គនាយករង (រយៈពេលបំពេញការងារចាប់ពី ១០ឆ្នាំឡើង) ចំពោះប្រធាននាយកដ្ឋាន(រយៈពេលបំពេញការងារចាប់ពី ៨ឆ្នាំឡើង) ចំពោះ

អនុប្រធាននាយកដ្ឋាន(រយៈពេលបំពេញការងារចាប់ពី ៥ឆ្នាំឡើង) ចំពោះ

ប្រធានការិយាល័យ(រយៈពេលបំពេញការងារចាប់ពី ៣ឆ្នាំឡើង)និងចំពោះអនុប្រធាការិយាល័យ

(រយៈពេលបំពេញការងារចាប់ពី ២ឆ្នាំឡើង)។

២).ចំពោះមន្ត្រីជំនាញគឺបទពិសោធន៍បំពេញការងារចាប់ពី ១ឆ្នាំឡើង។

| |
|---|
| - សមត្ថភាពបំពេញការងារ[4] ៖<br>○ ការទទួលខុសត្រូវ និងវិន័យការងារ (ឋានានុក្រម បទបញ្ជាផ្ទៃក្នុង ម៉ោងពេលធ្វើការ)<br>○ ការរៀបចំផែនការច្បាស់លាស់ និងការសម្រេចបានលទ្ធផល<br>○ ការបន្តអភិវឌ្ឍសមត្ថភាព ចំណេះដឹង និងជំនាញ<br>○ ការសហការការងារ និងស្មារតីជាក្រុម<br>○ គោរពការសម្ងាត់វិជ្ជាជីវៈនិងកាតព្វកិច្ចលក្ខណការណ៍<br>○ គំនិតផ្តួចផ្តើម ច្នៃប្រឌិត និងកែលម្អនីតិវិធី និងរបៀបរបបការងារ |
| - សមត្ថភាពវិជ្ជាជីវៈ[5] ៖<br>○ ............................................................................<br>○ ............................................................................<br>○ ............................................................................ |

4. គឺជាសមត្ថភាពស្នូលខាងឥរិយាបថនិងវិន័យសម្រាប់មន្ត្រីរាជការគ្រប់មុខតំណែង។

5. គឺជាសមត្ថភាពជំនាញសម្រាប់បំពេញតួនាទីនិងការទទួលខុសត្រូវឱ្យមានប្រសិទ្ធភាព។

# មុខតំណែង និងបទពិសោធន៍ការងារ

| ប្រភេទ ក្របខ័ណ្ឌ | | មុខតំណែង | ព្រះរាជក្រឹត្យលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | សេចក្ដីណែនាំ ២២០២ | តារាងតំរូវ | កម្រិតវប្បធម៌ |
|---|---|---|---|---|---|---|
| ក | ក.១ | អគ្គលេខាធិការ / អគ្គនាយក / អគ្គាធិការ / អភិបាលខេត្ត ក្រុង/ ឯកអគ្គរាជទូត-អគ្គរាជទូត / សាកលវិទ្យាធិការ / | អភិបាលរាជធានីខេត្ត= ៧ ឆ្នាំ (រដ្ឋបាលសាធារណៈ | | អគ្គនាយក = ១៣ឆ្នាំឡើង | បរិញ្ញាបត្រ |
| ក | ក.២ | អគ្គនាយករង / អគ្គាធិការរង / ប្រធាននាយកដ្ឋាន / អភិបាលរងខេត្តក្រុង / អគ្គទីប្រឹក្សា-ទីប្រឹក្សា-អគ្គកុងស៊ុល / សាកលវិទ្យាធិការរង /ព្រឹទ្ធបុរសមហាវិទ្យាល័យ / អធិការ | អភិបាលរងរាជធានីខេត្ត= ៥ ឆ្នាំ (រដ្ឋបាលសាធារណៈ) | | ប្រធាននាយកដ្ឋាន = ៨ឆ្នាំឡើង | បរិញ្ញាបត្រ |
| ក | ក.៣ | អនុប្រធានន.ដ្ឋាន / ប្រធានមន្ទីរ / អភិបាលក្រុងស្រុកខ័ណ្ឌ / នាយករដ្ឋបាលសាលារាជធានីខេត្ត / លេខាធិការទី១-កុងស៊ុល-លេខាធិការទី២-លេខាធិការទី៣-អនុកុងស៊ុល / ព្រឹទ្ធបុរសរងមហាវិទ្យាល័យ / អធិការរង / នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ / នាយកសាលាគរុកោសល្យខេត្ត ក្រុង / នាយកវិទ្យាល័យ | អភិបាលក្រុង ស្រុក ខណ្ឌ = ៥ ឆ្នាំ (រដ្ឋបាលសាធារណៈ) | ប្រធានមន្ទីរ អង្គភាព = ៥ឆ្នាំ | អនុប្រធាននាយកដ្ឋាន = ៥ឆ្នាំឡើង | បរិញ្ញាបត្រ |
| ខ | ខ.១ | ប្រធានការិ.( កណ្តាល ) / អនុប្រធានមន្ទីរ / អភិបាលរងក្រុង ស្រុក ខ័ណ្ឌ / នាយករងរដ្ឋបាលសាលារាជធានី ខេត្ត / នាយកទីចាត់ការសាលារាជធានី ខេត្ត / ប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត / កុងស៊ុល-លេខាធិការទី២-លេខាធិការទី៣ | អភិបាលរងក្រុង ស្រុក ខណ្ឌ = ៣ឆ្នាំ (រដ្ឋបាលសាធារណៈ) | នាយករងរដ្ឋបាលសាលារាជធានី ខេត្ត / នាយកទីចាត់ការសាលារាជធានី ខេត្ត/ ប្រធានអង្គភាពលទ្ធកម្មរាជធានីខេត្ត = ៥ ឆ្នាំ | ប្រធានការិយាល័យ = ៣ឆ្នាំឡើង | បរិញ្ញាបត្ររង |
| | | | | អនុប្រធានមន្ទីរ អង្គភាព = ៤ឆ្នាំ | | |
| | ខ.២ | អនុប្រធានការិ.( កណ្តាល ) / ប្រធានការិ.(មន្ទីរ / សាលាខេត្ត ក្រុង ) / នាយករងទីចាត់ការសាលារាជធានី ខេត្ត / អនុប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត / អនុកុងស៊ុល | | ប្រធានការិ.(មន្ទីរ / សាលាខេត្ត ក្រុង ) / នាយករងទីចាត់ការសាលារាជធានី ខេត្ត / អនុប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត = ៤ឆ្នាំ | អនុប្រធានការិយាល័យ = ២ឆ្នាំឡើង | |
| | ខ.៣ | អនុប្រធានការិ.(មន្ទីរ / សាលារាជធានី ខេត្ត ) / អនុព័ន្ធ-អនុព័ន្ធរងស្ថានទូត-ភ្នាក់ងារកុងស៊ុល / នាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ/ ប្រធានការិ.ក្រុង ស្រុក ខណ្ឌ (ស្រុកបតិបត្តិ) / ប្រធានអង្គភាពលទ្ធកម្មក្រុងស្រុកខណ្ឌ/ នាយកអនុវិទ្យាល័យ / នាយកសាលាបឋមសិក្សា / នាយកសាលាមត្តេយ្យសិក្សា | | អនុប្រធានការិ.(មន្ទីរ / សាលារាជធានី ខេត្ត ) = ៣ឆ្នាំ | | |
| | | | | នាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ/ ប្រធានការិ .ក្រុង ស្រុក ខណ្ឌ / ប្រធានអង្គភាពលទ្ធកម្មក្រុង ស្រុក ខណ្ឌ = ៤ឆ្នាំ | | |

# លក្ខខណ្ឌការងារ

- គឺជាផែនការអនុវត្តការងារប្រចាំឆ្នាំរបស់មន្ត្រីដែលផ្អែកលើការប្រគល់ភារកិច្ចដល់មន្ត្រីដោយអ្នកគ្រប់គ្រងផ្ទាល់។
- លក្ខខណ្ឌការងារនេះគឺដើម្បីផ្តល់ភាពច្បាស់លាស់ក្នុងការទទួលខុសត្រូវលើការងាររបស់មន្ត្រី ក្រោយពីមានការចូលរួមពិគ្រោះយោបល់រវាងមន្ត្រី និងអ្នកគ្រប់គ្រងផ្ទាល់ ដោយផ្អែកទៅលើផែនការការងារប្រចាំឆ្នាំរបស់អង្គភាពជាមូលដ្ឋាន។
- លក្ខខណ្ឌការងារនេះ ត្រូវរួមបញ្ចូលនូវគោលបំណងនៃគុណផល (ភារកិច្ច និងការទទួលខុសត្រូវ ព្រមទាំងសមត្ថភាពអនុវត្តការងារ) ការកំណត់សូចនាករវាយតម្លៃ (សូចនាករលម្អិត និងលទ្ធផលរំពឹងទុក) និងពេលវេលាអនុវត្ត។
- ជាទូទៅលក្ខខណ្ឌការងារត្រូវធ្វើឡើងនៅ ខែមករា។

## ឧបសម្ព័ន្ធ៤៖ ល័ក្ខខ័ណ្ឌការងារ

**ក្រសួង ស្ថាប័ន៖**.............................................................................**អង្គភាព៖**.............................................................................................

| | ឈ្មោះ | តួនាទី | កាលបរិច្ឆេទ | ហត្ថលេខា |
|---|---|---|---|---|
| សម្រាប់មន្ត្រី | | | | |
| សម្រាប់អ្នកគ្រប់គ្រងផ្ទាល់ | | | | |
| រយៈពេលអនុវត្ត | ☐ ០៦ ខែ | ☐ ១២ខែ | ☐ ......................... | |

| | គោលបំណងនៃគុណផល | សូចនាករវាយតម្លៃ [6] | | ពេលវេលា [7] |
|---|---|---|---|---|
| | | សូចនាករលម្អិត | លទ្ធផលរំពឹងទុក | |
| ១ | **ការកិច្ចនិងការទទួលខុសត្រូវ (ដែលអ្នកគ្រប់គ្រងផ្ទាល់ប្រគល់ឱ្យ)** | | | |
| | ១ | | | |
| | ២ | | | |
| | ៣ | | | |
| | ៤ | | | |
| | ៥ | | | |
| ២ | **សមត្ថភាពអនុវត្តការងារ** [8] | ១......................................<br>២......................................<br>៣...................................... | | |

---

[6] គឺជាការកំណត់នូវស្តង់ដា ឬលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ និងវាស់វែងនូវលទ្ធផលការងារនៃគោលបំណងគុណផលរបស់មន្ត្រីម្នាក់ៗ។ ការកំណត់ សូចនាករឱ្យបានត្រឹមត្រូវគឺទាមទាឱ្យមាននូវព័ត៌មានសម្រាប់ផ្ទៀងផ្ទាត់ទាក់ទងនឹងទិន្នន័យឬស្ថិតិ។ ចំពោះការកំណត់នូវសូចនាករលម្អិតគឺដើម្បីប្រើប្រាស់ ជាមធ្យោបាយក្នុង ការវាស់វែងលទ្ធផលរំពឹងទុក។ ក្រសួង ស្ថាប័ន ឬអង្គភាពអាចមានទម្រង់ផ្សេងៗគ្នានៃការកំណត់សូចនាករអាស្រ័យទៅតាមប្រភេទនៃការងារទទួលខុសត្រូវរបស់ខ្លួន។

[7] គឺជាការកំណត់រយៈពេលអនុវត្តផែនការសកម្មភាពដើម្បីសម្រេចឱ្យនូវគោលបំណងគុណផលនិងឆ្លើយតបសូចនាករវាយតម្លៃ។

[8] ជាតម្រូវការអភិវឌ្ឍសមត្ថភាពជំនាញ ដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាព។

# ការគ្រប់គ្រងវត្តមាន

- គឺជាយន្តការមួយក្នុងការតាមដានការអនុវត្តការងាររបស់មន្ត្រីដើម្បីលើកកម្ពស់មនសិការវិជ្ជាជីវៈនិងគុណផល។
- លទ្ធផលនៃការគ្រប់គ្រងវត្តមានរបស់មន្ត្រីនឹងត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃការវាយតម្លៃគុណផលមន្ត្រី។
- អ្នកគ្រប់គ្រងផ្ទាល់អាចកំណត់អំពីរបៀបរបបគ្រប់គ្រងវត្តមានដោយយោងទៅតាមបទប្បញ្ញត្តិជាធរមាន ព្រមទាំងតម្រូវការការងារ ទីកន្លែងការងារ និងតម្រូវការរបស់មន្ត្រី

**ឧបសម្ព័ន្ធ៥៖ ការគ្រប់គ្រងវត្តមាន**

បញ្ជីសម្រង់វត្តមានប្រចាំថ្ងៃរបស់មន្ត្រីរាជការស៊ីវិល

ថ្ងៃទី..............ខែ...............ឆ្នាំ២០១.....

| ល.រ | គោត្តនាមនិងនាម | ភេទ | តួនាទី | ហត្ថលេខា | | មកយឺត | ចេញមុន | លិខិតបញ្ជាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | ព្រឹក | ល្ងាច | | | | |
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| ៣ | | | | | | | | | |
| ៤ | | | | | | | | | |
| ៥ | | | | | | | | | |
| ៦ | | | | | | | | | |

-សរុបអវត្តមាន ៖ ................................................ នាក់

-មានច្បាប់ ៖ ................................................ នាក់

-ទំនេរគ្មានបៀវត្ស ៖ ................................................ នាក់

-ផ្សេងៗ ៖ ................................................

ធ្វើនៅ , ថ្ងៃទី ខែ ឆ្នាំ២០១.....

**ប្រធាន..........................**

# របាយការណ៍លទ្ធផលនិងការត្រួតពិនិត្យឡើងវិញ

❑មន្ត្រីដែលបានព្រមព្រៀងអនុវត្តការងារត្រូវរៀបចំរបាយការណ៍ជាទៀងទាត់ (ប្រចាំខែ ត្រីមាស ឆមាស ឬ ប្រចាំឆ្នាំ) តាមការកំណត់របស់អ្នកគ្រប់គ្រងផ្ទាល់ ស្តីពីលទ្ធផលការងាររបស់ខ្លួន រួចបញ្ជូនមកអ្នកគ្រប់គ្រងផ្ទាល់ ដើម្បីធ្វើការតាមដាននិងត្រួតពិនិត្យ លើការបំពេញការងាររបស់ខ្លួន។

**១. របាយការណ៍លទ្ធផល**

- របាយការណ៍លទ្ធផលត្រូវបង្ហាញអំពីសកម្មភាព/ការងារដែលបានគ្រោង លទ្ធផលដែលសម្រេចបាន និងរយៈពេលដែលបានអនុវត្ត ព្រមទាំងសកម្មភាពមិនទាន់បានសម្រេច និងបញ្ហាប្រឈមដែលជាឧបសគ្គរាំងស្ទះដល់ការអនុវត្តការងាររបស់មន្ត្រី។
- របាយការណ៍លទ្ធផលនេះ ត្រូវឆ្លុះបញ្ចាំងពីសកម្មភាពការងារ សូចនាករវាយតម្លៃ (សូចនាករលម្អិត និងលទ្ធផលរំពឹងទុក) និងពេលវេលាអនុវត្តដូចដែលបានកំណត់នៅក្នុងល័ក្ខខ័ណ្ឌការងាររវាងមន្ត្រីអនុវត្ត និងអ្នកគ្រប់គ្រងផ្ទាល់។

**២. ការត្រួតពិនិត្យឡើងវិញ**

- អ្នកគ្រប់គ្រងផ្ទាល់ត្រូវត្រួតពិនិត្យឡើងវិញជាប្រចាំ (ប្រចាំខែ ត្រីមាស ឆមាស ឬ ប្រចាំឆ្នាំ) លើរបាយការណ៍លទ្ធផលការងាររបស់មន្ត្រី តាមរយៈការពិគ្រោះយោបល់លើវឌ្ឍនភាពការងារ និងកំណត់បញ្ហាក្នុងការអនុវត្ត ព្រមទាំងផ្តល់ការណែនាំ និងមតិត្រឡប់ដល់មន្ត្រីអនុវត្ត។
- <u>ការត្រួតពិនិត្យឡើងវិញនេះនឹងជួយដោះស្រាយលើបញ្ហាប្រឈម តាមរយៈការកែសម្រួលផែនការការងារ ល័ក្ខខ័ណ្ឌការងារ ការអភិវឌ្ឍសមត្ថភាពមន្ត្រីនិងស្ថាប័ន និងការផ្តល់មធ្យោបាយសម្រាប់គាំទ្រដល់ការអនុវត្តការងារ។</u>

# ការវាយតម្លៃគុណផល

**លក្ខណៈវិនិច្ឆ័យ៖** ការវាយតម្លៃគុណផលត្រូវធ្វើឡើងជាប្រចាំ (០៣ខែ ០៦ខែ ០៩ខែ ឬ ១២ខែ) ទៅតាមការកំណត់របស់អង្គភាព។ ការវាយតម្លៃត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យចម្បងចំនួន ២ ៖

**(១) លទ្ធផលការងារ (៦០ពិន្ទុ)**

- កម្រិតសម្រេចបានការងារ (២០ពិន្ទុ)
- ភាពទាន់ពេលវេលា (២០ពិន្ទុ)
- កម្រិតនៃភាពលំបាក (២០ពិន្ទុ)

**(២) សមត្ថភាពអនុវត្តការងារ (៤០ពិន្ទុ)**

- ឥរិយាបថ និងវិន័យ (២០ពិន្ទុ)
- សមត្ថភាពវិជ្ជាជីវៈ (១០ពិន្ទុ)
- ភាពជាអ្នកដឹកនាំ (១០ពិន្ទុ)

- **លទ្ធផលការងារ** គឺសំដៅដល់ការសម្រេចការងារទៅតាមលទ្ធផលរំពឹងទុក និងកាលវិភាគអនុវត្តដែលបានកំណត់ក្នុងលក្ខខ័ណ្ឌការងាររវាងមន្ត្រី និងអ្នកគ្រប់គ្រងផ្ទាល់។ ការវាយតម្លៃលទ្ធផលការងារត្រូវផ្តោតលើ កម្រិតនៃការសម្រេចបានការងារ ភាពទាន់ពេលវេលា និងកម្រិតនៃភាពលំបាកក្នុងការអនុវត្តការងារ។
- **សមត្ថភាពអនុវត្តការងារ** គឺសំដៅដល់ឥរិយាបថ និងវិន័យការងាររបស់បុគ្គល សមត្ថភាពវិជ្ជាជីវៈ និងភាពជាអ្នកដឹកនាំ ដែលចាំបាច់សម្រាប់ការបំពេញការងារឱ្យសម្រេចបានលទ្ធផល។

# នីតិវិធីក្នុងការវាយតម្លៃ

តើខ្ញុំបានសម្រេចការងារអ្វីខ្លះកន្លងមក?

តើត្រូវពិនិត្យលើលក្ខណៈវិនិច្ឆ័យអ្វីខ្លះ?
១.លទ្ធផលការងារ (៦០ពិន្ទុ)
២.សមត្ថភាពអនុវត្តការងារ (៤០ពិន្ទុ)

១.មន្ត្រីបំពេញលទ្ធផលការងារតារាងវាយតម្លៃ រួចបញ្ជូនទៅអ្នកគ្រប់គ្រងផ្ទាល់

២. អ្នកគ្រប់គ្រងផ្ទាល់ពិនិត្យតារាងវាយតម្លៃ កំណត់ពីរបៀបដាក់ពិន្ទុ និងផ្តល់ចំណាត់ថ្នាក់ និងមតិយោបល់លើការដាក់ពិន្ទុ



៣.មន្ត្រីពិនិត្យមើលលទ្ធផលពិន្ទុវាយតម្លៃនិងពិភាក្សាជាមួយអ្នកគ្រប់គ្រងផ្ទាល់



៤.មន្ត្រីមិនឯកភាព...

៤.មន្ត្រីឯកភាពជាមួយនឹងពិន្ទុវាយតម្លៃនេះ

៥.បញ្ជូនលទ្ធផលវាយតម្លៃទៅអ្នកគ្រប់គ្រងខ្ពស់បន្ទាប់ដើម្បីពិនិត្យនិងសម្រេច



៦.មន្ត្រីឯកភាព

៦.មន្ត្រីមិនឯកភាព.....

៧.ក្រសួងស្ថាប័នបង្កើតគណៈកម្មការដើម្បីពិនិត្យចុងក្រោយលើលទ្ធផលវាយតម្លៃ



# នីតិវិធីក្នុងការវាយតម្លៃ (ត)

ធ្វើការវាយតម្លៃគុណផលជាប្រចាំ (០៣ ,០៦, ០៩ ឬ១២ខែ)

លក្ខណៈវិនិច្ឆ័យវាយតម្លៃគុណផល

**លទ្ធផលការងារ (៦០ពិន្ទុ)**

- កម្រិតសម្រេចបានការងារ(២០ពិន្ទុ)
- ភាពទាន់ពេលវេលា(២០ពិន្ទុ)
- កម្រិតនៃភាពលំបាក(២០ពិន្ទុ)

**សមត្ថភាពអនុវត្តការងារ (៤០ពិន្ទុ)**

- ឥរិយាបថ និងវិន័យ(២០ពិន្ទុ)
- សមត្ថភាពវិជ្ជាជីវៈ(១០ពិន្ទុ)
- ភាពជាអ្នកដឹកនាំ(១០ពិន្ទុ)

| | | | | |
|---|---|---|---|---|
| ចំណាត់ថ្នាក់(៥) ល្អប្រសើរ (៨១-១០០ពិន្ទុ) | ចំណាត់ថ្នាក់(៤) ល្អ (៦០-៨០ពិន្ទុ) | ចំណាត់ថ្នាក់(៣) មធ្យម (៤១-៦០ពិន្ទុ) | ចំណាត់ថ្នាក់(២) ត្រូវកែលម្អ (២១-៤០ពិន្ទុ) | ចំណាត់ថ្នាក់ (១) ទាប (០-២០ពិន្ទុ) |

# នីតិវិធីក្នុងការវាយតម្លៃ

ទី១.

- មន្ត្រីអនុវត្តត្រូវបំពេញលទ្ធផលការងារដែលសម្រេចបាន (យោងតាមរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ឬប្រចាំឆ្នាំ ដូចក្នុងឧបសម្ព័ន្ធ ៦) បញ្ចូលទៅក្នុងតារាងនៃការវាយតម្លៃ រួចបញ្ជូនមកអ្នកគ្រប់គ្រងផ្ទាល់ដើម្បីធ្វើការវាយតម្លៃ។
- អ្នកគ្រប់គ្រងផ្ទាល់ត្រូវពិនិត្យមើលលើការបំពេញលទ្ធផលការងារដែលសម្រេចបាននេះ។ ទន្ទឹមគ្នានេះ អ្នកគ្រប់គ្រងផ្ទាល់ត្រូវកំណត់អំពីរបៀបនៃការដាក់ពិន្ទុដោយផ្តោតលើលក្ខណៈវិនិច្ឆ័យខាងលើ ទាំងលើលទ្ធផលការងារ (៦០ពិន្ទុ) និងសមត្ថភាពអនុវត្តការងារ (៤០ពិន្ទុ) និងដោយមានផ្តល់ជាមតិយោបល់ទៅលើការដាក់ពិន្ទុរបស់ខ្លួន ព្រមទាំងផ្តល់ជាចំណាត់ថ្នាក់ទៅលើពិន្ទុសរុប។
- លទ្ធផលនៃពិន្ទុវាយតម្លៃនេះ មន្ត្រីអនុវត្តមានសិទ្ធិក្នុងការពិនិត្យ និងពិភាក្សាជាមួយអ្នកគ្រប់គ្រងផ្ទាល់ ដោយអាចផ្តល់ជាមតិឯកភាព ឬ មិនឯកភាពចំពោះលទ្ធផលនៃការវាយតម្លៃនេះ (ដូចក្នុងឧបសម្ព័ន្ធ ៧)។

ទី២.

- ក្នុងករណីមិនមានការឯកភាពរវាងមន្ត្រីអនុវត្តនិងអ្នកគ្រប់គ្រងផ្ទាល់ លទ្ធផលនៃការវាយតម្លៃនេះត្រូវបញ្ជូនទៅអ្នកគ្រប់គ្រងខ្ពស់បន្ទាប់ដើម្បីពិនិត្យនិងសម្រេច។

ទី៣.

- ក្រោយពីការសម្រេចរបស់អ្នកគ្រប់គ្រងខ្ពស់បន្ទាប់ទៅលើលទ្ធផលនៃការវាយតម្លៃគុណផលខាងលើ បើសិនជានៅតែមិនមានការឯកភាពរវាងមន្ត្រីអនុវត្ត និងអ្នកគ្រប់គ្រងផ្ទាល់ ក្រសួង ស្ថាប័នអាចបង្កើតគណៈកម្មការមួយតាមការចាំបាច់ ដើម្បីពិនិត្យចុងក្រោយលើលទ្ធផលនៃការវាយតម្លៃនេះ។

# គោលការណ៍នៃការផ្តល់ចំណាត់ថ្នាក់ ១-៥

- ❖ ចំណាត់ថ្នាក់ (៥) = ល្អប្រសើរ (ពិន្ទុ ៨១ ទៅ ១០០)
  - ការសម្រេចលទ្ធផលការងារ (ទាំងបរិមាណ និងគុណភាព ដោយផ្តោតលើ កម្រិតសម្រេចបានការងារ ភាពទាន់ពេលវេលា និងកម្រិតនៃភាពលំបាក) ព្រមទាំងមានឥរិយាបថនិងវិន័យ សមត្ថភាពវិជ្ជាជីវៈនិងភាពជាអ្នកដឹកនាំ លើសពីការរំពឹងទុក និងលើសសហសេវិកដទៃទៀត (ដែលស្ថិតក្នុងតំណែងនិងបៀវត្សរ៍ដូចគ្នា)។
- ❖ ចំណាត់ថ្នាក់ (៤) = ល្អ (ពិន្ទុ ៦១ ទៅ ៨០)
  - ការសម្រេចលទ្ធផលការងារ (ទាំងបរិមាណ និងគុណភាព ដោយផ្តោតលើ កម្រិតសម្រេចបានការងារ ភាពទាន់ពេលវេលា និងកម្រិតនៃភាពលំបាក) ព្រមទាំងមានឥរិយាបថនិងវិន័យ សមត្ថភាពវិជ្ជាជីវៈ និងភាពជាអ្នកដឹកនាំ លើសសហសេវិកដទៃទៀត (ដែលស្ថិតក្នុងតំណែងនិងបៀវត្សរ៍ដូចគ្នា)។
- ❖ ចំណាត់ថ្នាក់ (៣) = មធ្យម (ពិន្ទុ ៤១ ទៅ ៦០)
  - ការសម្រេចលទ្ធផលការងារ (ទាំងបរិមាណ និងគុណភាព ដោយផ្តោតលើ កម្រិតសម្រេចបានការងារ ភាពទាន់ពេលវេលា និងកម្រិតនៃភាពលំបាក) ព្រមទាំងមានឥរិយាបថនិងវិន័យ សមត្ថភាពវិជ្ជាជីវៈ និងភាពជាអ្នកដឹកនាំ ឆ្លើយតបនឹងមុខតំណែង និងលទ្ធផលរំពឹងទុក។
- ❖ ចំណាត់ថ្នាក់ (២) = ត្រូវកែលម្អ (ពិន្ទុ ២១ ទៅ ៤០)
  - ការសម្រេចលទ្ធផលការងារ (ទាំងបរិមាណ និងគុណភាព ដោយផ្តោតលើ កម្រិតសម្រេចបានការងារ ភាពទាន់ពេលវេលា និងកម្រិតនៃភាពលំបាក) ព្រមទាំងមានឥរិយាបថនិងវិន័យ សមត្ថភាពវិជ្ជាជីវៈ និងភាពជាអ្នកដឹកនាំ មិនទាន់ឆ្លើយតបនឹងមុខតំណែង និងលទ្ធផលរំពឹងទុក។
- ❖ ចំណាត់ថ្នាក់ (១) = គុណផលទាប (ពិន្ទុ ០ ទៅ ២០)
  - ការសម្រេចលទ្ធផលការងារ (ទាំងបរិមាណ និងគុណភាព ដោយផ្តោតលើ កម្រិតសម្រេចបានការងារ ភាពទាន់ពេលវេលា និងកម្រិតនៃភាពលំបាក) ព្រមទាំងមានឥរិយាបថនិងវិន័យ សមត្ថភាពវិជ្ជាជីវៈ និងភាពជាអ្នកដឹកនាំ នៅមិនទាន់ឆ្លើយតបនឹងមុខតំណែង និងលទ្ធផលរំពឹងទុក និងនៅបន្តកម្រិតទាប ក្រោយមានការត្រួតពិនិត្យ និងពិគ្រោះយោបល់ណែនាំ។

# លទ្ធផលនៃការវាយតម្លៃ

លទ្ធផលសរុបនៃការវាយតម្លៃគុណផលរបស់មន្ត្រីត្រូវបែងចែកជា ៥ ចំណាត់ថ្នាក់ដូចខាងក្រោម៖

- ចំណាត់ថ្នាក់ **ល្អប្រសើរ** មានឧបនិស្ស័យនឹងទទួលបាន ៖
  - គ្រឿងឥស្សរិយយស
  - ការតែងតាំងកាន់មុខតំណែងខ្ពស់បន្ទាប់
  - ប្រាក់រង្វាន់លើកទឹកចិត្ត
  - ការអភិវឌ្ឍសមត្ថភាព (ការបណ្តុះបណ្តាល ការបង្វឹក ផែនការអាជីព)
  - ការឡើងថ្នាក់ (ស្វ័យប្រវត្តិ)
- ចំណាត់ថ្នាក់ **ល្អ** មានឧបនិស្ស័យនឹងទទួលបាន ៖
  - ប័ណ្ណសរសើរ
  - ការឡើងថ្នាក់ (ស្វ័យប្រវត្តិ)
  - ការអភិវឌ្ឍសមត្ថភាព (ការបណ្តុះបណ្តាល ការបង្វឹក ផែនការអាជីព)

- ចំណាត់ថ្នាក់ **មធ្យម** មានឧបនិស្ស័យនឹងទទួលបាន ៖

- ❑ អាចឡើងថ្នាក់បណ្តុះបណ្តាល និងបង្កើនសមត្ថភាពជំនាញបន្ថែមរយៈពេលខ្លី

- ចំណាត់ថ្នាក់ **ត្រូវកែលម្អ** មានឧបនិស្ស័យនឹងទទួលបាន ៖

- ❑ ការបណ្តុះបណ្តាល និងការបង្កើនសមត្ថភាពជំនាញបន្ថែមរយៈពេលយូរ ការបង្អាក់ឡើងថ្នាក់

- ចំណាត់ថ្នាក់ **គុណផលទាប** អាចទទួលបាន ៖

- ❑ ការបណ្តុះបណ្តាល និងបង្កើនសមត្ថភាពជំនាញបន្ថែមរយៈពេលយូរ
- ❑ ការបង្អាក់ការឡើងថ្នាក់
- ❑ វិធានការរដ្ឋបាលតាមករណីចាំបាច់។

# លទ្ធផលនៃការវាយតម្លៃគុណផល



# ឧបសម្ព័ន្ធ៧៖ តារាងគំរូនៃការវាយតម្លៃគុណផល

| ឈ្មោះ (មន្ត្រីអនុវត្ត) | អង្គភាព/ក្រសួង ស្ថាប័ន | មុខតំណែង | ឋានន្តរស័ក្តិ | កាលបរិច្ឆេទតែងតាំងក្នុងមុខតំណែងបច្ចុប្បន្ន |
|---|---|---|---|---|
| | | | | |
| រយៈពេលវាយតម្លៃគុណផល | ☐ ០៣ ខែ | ☐ ០៦ ខែ | ☐ ០៩ខែ | ☐ ១២ខែ |

| លទ្ធផលវាយតម្លៃ | ល្អប្រសើរ (៨១-១០០) ☐ | ល្អ (៦១-៨០) ☐ | មធ្យម (៤១-៦០) ☐ | ត្រូវកែលម្អ (២១-៤០) ☐ | គុណផលទាប (០-២០) ☐ |
|---|---|---|---|---|---|

I **ការវាយតម្លៃលើលទ្ធផលការងារ (៦០ ពិន្ទុ)** (ខ្លឹមសារនេះដកស្រង់ពីល័ក្ខខ័ណ្ឌការងារ ដូចក្នុងឧបសម្ព័ន្ធ៤)

| | បំពេញដោយមន្ត្រីអនុវត្ត | | បំពេញដោយអ្នកគ្រប់គ្រងផ្ទាល់ | | | |
|---|---|---|---|---|---|---|
| ល.រ | គោលបំណងនៃគុណផល [9] | លទ្ធផលដែលសម្រេចបាន[10] | កម្រិតនៃការសម្រេចការងារ[11] (២០ ពិន្ទុ) | ភាពទាន់ពេលវេលា[12] (២០ ពិន្ទុ) | កម្រិតនៃភាពលំបាក[13] (២០ ពិន្ទុ) | មតិយោបល់ |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ការងារបន្ថែម | | | | | | |
| ការងារបន្ថែម[14] | | | | | | |
| ពិន្ទុសរុបលើលទ្ធផលការងារ | | | | | | |

## II ការវាយតម្លៃលើសមត្ថភាពអនុវត្តការងារ (៤០ ពិន្ទុ)

| ល.រ | សមាសធាតុវាយតម្លៃ | ពិន្ទុផ្តល់ដោយ<br>អ្នកគ្រប់គ្រងផ្ទាល់ | មូលហេតុ |
|---|---|---|---|
| ១ | **វិន័យ  និងវិន័យ (២០ពិន្ទុ)** | | |
| | គោរពវិន័យការងារ ម៉ោងពេលធ្វើការ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គភាព | | |
| | ស្មារតីទទួលខុសត្រូវ | | |
| | ការគោរពឋានានុក្រមការងារ និងគោរពការសម្ងាត់វិជ្ជាជីវៈនិងភាតព្វកិច្ចលក្ខណការណ៍ | | |
| ២ | **សមត្ថភាពវិជ្ជាជីវៈ (១០ពិន្ទុ)** | | |
| | សមត្ថភាពបំពេញការងារ | | |
| | អភិវឌ្ឍសមត្ថភាព ចំណេះដឹង និងជំនាញ | | |
| | មានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត (កែលម្អសកម្មភាពការងារ ដើម្បីប្រសិទ្ធភាព និងមធ្យម) | | |
| ៣ | **ភាពជាអ្នកដឹកនាំ (១០ពិន្ទុ)** | | |
| | សហការការងារជាមួយមន្ត្រីរាជការដទៃដើម្បី សម្រេចលទ្ធផលរួម/ស្មារតីជាក្រុម | | |
| | ទំនាក់ទំនងអន្តរបុគ្គល | | |
| | សមត្ថភាពអនុវត្តការងារក្រោមសម្ពាធ | | |

| ពិន្ទុសរុប (I+II) | ចំណាត់ថ្នាក់ |
|---|---|
| | |

[14] ការប្រគល់ភារកិច្ចឱ្យតាមការចាំបាច់

| III . អ្នកគ្រប់គ្រងផ្ទាល់អាចជ្រើសរើសប្រភេទនៃការលើកទឹកចិត្តលើសពីមួយ (តែមិនឱ្យលើសពីបី) ដោយផ្អែកទៅតាមចំណាត់ថ្នាក់នៃការវាយតម្លៃ ។ | ☑ | មតិយោបល់បន្ថែមរបស់អ្នកគ្រប់គ្រងផ្ទាល់ |
|---|---|---|
| ត្រៀមសម្រាប់ទទួលគ្រឿងឥស្សរិយយស | | |
| ត្រៀមសម្រាប់ទទួលការតែងតាំងកាន់មុខដំណែងខ្ពស់បន្ទាប់ | | |
| ត្រៀមសម្រាប់ទទួលប្រាក់រង្វាន់លើកទឹកចិត្ត | | |
| ត្រៀមសម្រាប់ទទួលការអភិវឌ្ឍសមត្ថភាព ( ការបណ្តុះបណ្តាល ការបង្វឹក ផែនការអាជីព ) | | |
| ឡើងថ្នាក់ ( ស្វ័យប្រវត្តិ ) | | |
| ត្រៀមសម្រាប់ទទួលប័ណ្ណសរសើរ | | |
| បណ្តុះបណ្តាល និងបង្កើនសមត្ថភាពជំនាញបន្ថែមរយៈពេលខ្លី | | |
| បណ្តុះបណ្តាល និងបង្កើនសមត្ថភាពជំនាញបន្ថែមរយៈពេលយូរ | | |
| បង្អកការឡើងថ្នាក់ | | |
| វិធានការរដ្ឋបាលតាមករណីចាំបាច់ | | |

IV .ក្នុងករណីមិនមានការឯកភាពលើការវាយតម្លៃ

| | ឈ្មោះ | តួនាទី | កាលបរិច្ឆេទ | ហត្ថលេខា | មតិយោបល់ |
|---|---|---|---|---|---|
| មន្ត្រីអនុវត្ត | | | | | |
| អ្នកវាយតម្លៃ ឬអ្នកគ្រប់គ្រងផ្ទាល់ | | | | | |
| សម្រេចដោយអ្នកគ្រប់គ្រងខ្ពស់បន្ទាប់ | | | | | |

# វិធីសាស្ត្រអនុវត្ត

- គ្រប់ក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវជានាចំពោះការគោរព និងការអនុវត្តគោលការណ៍គ្រឹះទាំង ៥ (បរិយាកាសឬវប្បធម៌ស្ថាប័ន ភាពស៊ីសង្វាក់គ្នា ការចូលរួម គុណផល និងសមត្ថភាពអនុវត្ត) ដោយមានការសម្របសម្រួលនិងជំនួយបច្ចេកទេសតាមការចាំបាច់

ពីលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

- ក្នុងដំណាក់ដំបូង៖ អនុវត្តចាប់ពីមុខតំណែងអភិបាលខេត្ត-រាជធានី អគ្គនាយក អគ្គលេខាធិការ និងប្រធាននាយកដ្ឋាន ព្រមទាំងស្ថាប័ន/អង្គភាពដែលមានសមាសធាតុប្រព័ន្ធគ្រប់គ្រងគុណផល ដូចជាគ្រឹះស្ថានសាធារណៈ ទីភ្នាក់ងារប្រតិបត្តិការពិសេស និងច្រកចេញចូលតែមួយ។

- ដំណាក់កាលបន្ទាប់៖ គ្រប់មុខតំណែង និងមន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រោយពីមានការពិគ្រោះយោបល់ទូលាយរវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់

រដ្ឋបាលសាធារណៈ ជាមួយនឹងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

# តួនាទីនិងការទទួលខុសត្រូវ

- ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការដាក់ឱ្យអនុវត្ត ប្រព័ន្ធគ្រប់គ្រងគុណផលនៅតាមក្រសួង ស្ថាប័នរបស់ខ្លួន (តាមវដ្តនៃផែនការការងារនិងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន)។
- ក្រសួង ស្ថាប័នត្រូវទទួលខុសត្រូវផងដែរនៅក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យឡើងវិញលើការអនុវត្ត ប្រព័ន្ធគ្រប់គ្រងគុណផល ដោយមានការសហការ សម្របសម្រួល និងផ្តល់ជំនួយបច្ចេកទេស តាមការចាំបាច់ពីលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។
- លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ជាសេនាធិការ តាមរយៈការផ្សព្វផ្សាយឯកសារណែនាំ ការបណ្តុះបណ្តាលសមត្ថភាពអនុវត្ត ការប្រមូលចងក្រងលទ្ធផលនៃការត្រួតពិនិត្យនិងវាយតម្លៃ ព្រមទាំងការរៀបចំជាវេទិកានៃការចែករំលែកបទពិសោធន៍នៃការអនុវត្តល្អៗទាំងក្នុងប្រទេសនិងអន្តរជាតិ។
- ចំពោះប្រតិបត្តិការជាប្រចាំនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលជាការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងផ្ទាល់នៅតាមអង្គភាពនិងមន្ត្រីរបស់ខ្លួន (តម្លាភាព គណនេយ្យភាព ការចូលរួម សុក្រឹតភាព និងសច្ចធម៌ក្នុងស្មារតីទទួលខុសត្រូវខ្ពស់និងភាពជាអ្នកដឹកនាំ)។

# គន្ថនិទ្ទេស

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការប្រកាសឱ្យការប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ព្រះរាជក្រឹត្យលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

- ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៦  ខែមេសា  ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- អនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស។
- អនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការស្ថិតនៅក្រៅក្របខ័ណ្ឌដើមចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ។
- ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

- ចំណេះដឹងមុខងារសាធារណៈ **ពេជ្រ ប៊ុនធិន -ស៊ិន សុឃន- សិក ហេងឡុង** បោះពុម្ពលើកទី១ ឆ្នាំ២០១០
- អនុក្រឹត្យលេខ៣១ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែប្រែតម្លៃឯកតាសន្ទស្សន៍បៀវត្សមូលដ្ឋានមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២០
- លិខិតលេខ៥៤២០ មស.នក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរំកិលអាយុឱ្យចូលនិវត្តន៍ដល់អាយុ៦០ឆ្នាំ សម្រាប់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតលេខ១២៦/២៤មស.គកស ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ សេចក្តីណែនាំអន្តរក្រសួងស្តីពី ការបើកផ្តល់បៀវត្ស និងការគ្រប់គ្រងការផ្ទេរបុគ្គលិកអប់រំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- លិខិតលេខ១២៨២/២៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៥ ស្តីពីសំណើសុំផ្អាកការផ្ទេរមន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញការងារនៅតាមមណ្ឌលសុខភាព។

# សូមអរគុណ!